# នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Oct-2017, 08:00
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ (ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់)

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ៖ សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# បណ្តឹងទាមទារចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សំណុំរឿង០០២/០២ ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

ចៅក្រម Claudia FENZ

Original EN: 01485878-01485911

ស៊ិន សុវ៉ន

សំ សុគង់

វ៉ែន ពៅ

ទី ស្រីនណា

Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

Olivier BAHOUGNE

*បណ្តឹងទាមទារចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណាង នៅក្នុងសំណុំរឿង ០០២/០២ ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់*

Original EN: 01485878-01485911

# មាតិកា

I. សេចក្តីផ្តើម ....................5
ក. ក្របខណ្ឌគតិយុត្តិ ....................6
ខ. វិធីសាស្ត្រ ....................7
គ. ទិដ្ឋភាពរួមអំពីសារណា និងសំណើទាក់ទងនឹងការរៀបអង្គាសមូលនិធិ ....................10
II. គម្រោងដែលបានទទួលការឧបត្ថម្ភថវិកាពេញលេញ និងគាំទ្រដោយសហមេធាវីនាំមុខជាតិ និងអន្តរជាតិ ....................12
ក. ការធានាអំពីការមិនកើតឡើងជាថ្មី ....................12
(១) គម្រោង App-Learning on Khmer Rouge History ....................14
(២) ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ ....................16
(៣) គម្រោងអណ្តើក៖ គម្រោងអន្តរព័ត៌មានប្រកបដោយភាពច្នៃប្រឌិត ដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រ និងភាពក្លាហានរបស់ពលរដ្ឋនៅកម្ពុជា ....................17
ខ. ការធានាអំពីការមិនកើតឡើងវិញជាថ្មី (គម្រោងផ្តល់ប្រយោជន៍ដល់ក្រុមដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះជាក់លាក់) ....................19
(៤) គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម ....................21
(៥) ផ្កាស្លាក្រោមអង្គការ ....................22
(៦) សំឡេងពីជនជាតិភាគតិច៖ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តិមកលើជនជាតិភាគតិចវៀតណាម និងចាម ដែលបានរស់នៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងរបបខ្មែរក្រហម ....................24
គ. ការពេញចិត្ត ....................26
(៧) រឿងរ៉ាវដែលមិនធ្លាប់បានគេដឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានចូលរួមក្នុងសំណុំរឿង ០០២/ ០២ នៅ អ.វ.ត.ក ....................27
(៨) ពេលវេលាដែលត្រូវចងចាំ៖ ការប្រកួតប្រជែងរបស់យុវជនក្នុងការតាក់តែងចម្រៀង ស្តីពីការចងចាំនៅកម្ពុជា ឆ្នាំ ២០១៦ ....................29
(៩) ផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់ ....................31

(១០) ការចូលមើលកំណត់ហេតុតុលាការស្តីពីការកាត់សេចក្តីខ្មែរក្រហម និងសម្ភាររបស់ដើមបណ្តឹង រដ្ឋប្បវេណីនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹង អ.វ.ត.ក (LDC) ....................32
ឃ. ការស្តារនីតិសម្បទា ....................34
(១១) ការព្យាបាល និងការផ្សះផ្សាសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ....................36
III. គម្រោងដែលបានទទួលការឧបត្ថម្ភថវិកាពេញលេញ និងគាំទ្រដោយសហមេធាវីនាំមុខអន្តរជាតិ .....37
(១២) ការអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិច ....................38
IV. គម្រោងដែលពុំបានទទួលការឧបត្ថម្ភថវិកាពេញលេញ ....................39
(១៣) គម្រោងលើកកម្ពស់សុខភាព និងសុខុមាលភាពផ្លូវចិត្ត និងកាត់បន្ថយហានិភ័យនៃភាពក្រីក្រ និងការកាត់ផ្តាច់ពីសង្គមនៃដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងបុគ្គលចាស់ជរាដែលងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា ....................40
(១៤) វេទិកាអប់រំជាសាធារណៈ និងការតាំងពិពណ៌ជាអចិន្ត្រៃយ៍អំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ....................41
(១៥) ប្រជាជនជនជាតិដើមភាគតិចកម្ពុជា និងប៉ុល ពត ....................43
(១៨) ការចូលមើល និងការផ្សព្វផ្សាយបណ្ណសារច្បាប់ និងប្រវត្តិសាស្ត្រទាក់ទងនឹងខ្មែរក្រហម..44
V. គម្រោងដែលស្នើឡើងដោយអង្គភាពគាំពារជនរងគ្រោះ ....................45
(១៧) ការបោះពុម្ពផ្សាយ និងការចែកចាយសាលក្រមទាំងមូល និងសង្ខេបនៃសំណុំរឿង ០០២/០២ ដល់ដើមបណ្តឹងរដ្ឋប្បវេណី ....................45
(១៨) មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍នៅភ្នំសំពៅ និងការធ្វើទុកបុកម្នេញលើពុទ្ធសាសនិកជនក្នុងរបបខ្មែរក្រហម ....................47
V. សំណើ ....................48

# I. សេចក្ដីផ្ដើម

1. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី (“សហមេធាវីនាំមុខ”) បានដាក់សារណាបញ្ចប់របស់សហមេធាវីនាំមុខ ក្នុងសំណុំរឿង០០២/០២ (“សារណាបញ្ចប់”) នៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧។ នៅក្នុងសារណានោះ សហមេធាវីនាំមុខតំណាងបានផ្ដល់សេចក្ដីពិពណ៌នាអំពីទិដ្ឋភាពរួមនៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២/០២ និងបានបញ្ជាក់អំពីព្យសនកម្មដែលដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរងទាក់ទងនឹងវគ្គនីមួយៗនៃសវនាការជំនុំជម្រះក្នុងវិសាលភាពនៃសំណុំរឿង០០២/០២[1]។ ដូចដែលអង្គជំនុំជម្រះបានបង្គាប់ សហមេធាវីនាំមុខសូមដាក់បណ្ដឹងទាមទារចុងក្រោយសម្រាប់សំណង ដែលសហមេធាវីនាំមុខស្នើឱ្យអង្គជំនុំជម្រះអនុម័តទៅលើគម្រោងចំនួន ១៧ ជាការការផ្ដល់សំណងរបស់តុលាការសម្រាប់ជាប្រយោជន៍នៃដើមបណ្ដឹងរដ្ឋប្បវេណីចំពោះព្យនសកម្មដែលពួកគាត់បានទទួលរងដោយសារឧក្រិដ្ឋកម្មដែលត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២[2]។ សហមេធាវីនាំមុខអន្តរជាតិស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងអនុម័តទៅលើគម្រោងបន្ថែមមួយទៀត[3]។

2. សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងបណ្ដឹងទាមទារចុងក្រោយ ត្រូវបានរៀបចំឡើង ដើម្បីដាក់ឱ្យពិនិត្យមើលរួមគ្នា។ សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលបង្ហាញពីទំនាក់ទំនងរវាងព្យសនកម្មដែលទទួលរងដោយសារឧក្រិដ្ឋកម្មក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ហើយបណ្ដឹងទាមទារចុងក្រោយបង្ហាញអំពីគម្រោងសំណងដែលឆ្លើយតបទៅនឹងព្យសនកម្មទាំងនោះ។ សហមេធាវីនាំមុខក៏បានស្នើឱ្យពិនិត្យមើលទិដ្ឋភាពរួមនៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ដែលបានលើកឡើងនៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលនេះ ជាពិសេសទាក់ទងនឹងផ្នែកទីពីរនៃសកម្មភាពរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ទាក់ទងនឹងលទ្ធភាពក្នុងការស្វែង

---

[1] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២/០២, **E457/6/2**, ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧។

[2] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង, សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងសេចក្ដីកិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង០០២/០២, **E449/1,** ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលា ដំបូងស្ដីពី សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលកំណត់សម្រាប់ការសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងសេចក្ដីកិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង០០២/០២, **E457/6,** ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧។

[3] សូមមើល,*ដូចខាងក្រោម* ផ្នែកទី៣។

រកសំណងសមូហភាព និងសំណងផ្លូវចិត្ត សម្រាប់ព្យសនកម្មដែលបានទទួលដោយសារឧក្រិដ្ឋកម្ម ដែលត្រូវបានជំនុំជម្រះ[4]។

## ក. ក្របខណ្ឌគតិយុត្តិ

3. វិធាន២៣ ស្ទួន៤ (១) នៃវិធានផ្ទៃក្នុង ចែងថា “នៅពេលដែលអង្គជំនុំជម្រះរកឃើញអំពីពិរុទ្ធភាព របស់ជនជាប់ចោទ អង្គជំនុំជម្រះអាចសម្រេចផ្តល់ឲ្យតែសំណងផ្លូវចិត្ត និងជាសមូហភាព ទៅដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ”។ តាមគោលបំណងនៃវិធានទាំងនេះ សំណងផ្លូវចិត្ត និងសមូហភាព គឺជាវិធានការទាំងឡាយដែល (ក) ទទួលស្គាល់នូវការខូចខាតដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរងដោយសារការប្រព្រឹត្តិនូវបទឧក្រិដ្ឋរបស់ជនជាប់ចោទដែលត្រូវបានផ្តន្ទាទោស និង (ខ) ផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងការខូចខាតនេះ។ ផលប្រយោជន៍ទាំងនេះមិនត្រូវមានទម្រង់នៃសំណងជាប្រាក់ដល់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ”។

4. សហមេធាវីនាំមុខបញ្ជាក់ថា សំណងជាប្រាក់ជាលក្ខណៈបុគ្គល ត្រូវបានហាមឃាត់យ៉ាងច្បាស់ដោយក្របខណ្ឌគតិយុត្តិ អ.វ.ត.ក[5]។ សហមេធាវីនាំមុខក៏បានពិពណ៌នានៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលលើចំណុចថាតើវិធានផ្ទៃក្នុងចែងដូចម្តេចអំពីទម្រង់ពីរដាច់ដោយឡែកពីគ្នានៃការអនុវត្តការផ្តល់សំណង ដោយការអនុវត្តសំណងបែបនោះត្រូវបានធ្វើឡើងប្រឆាំងនឹងពិរុទ្ធជន និងជាបន្ទុករបស់ពិរុទ្ធជន ឬការអនុវត្តសំណងត្រូវបានរៀបចំឡើង និងផ្តល់មូលនិធិដោយភាគីខាងក្រៅ ដោយពុំមានការផ្តល់សំណងពីពិរុទ្ធជនឡើយ[6]។ សំណើសុំសំណងទាំងអស់ដែលលើកឡើងនៅក្នុងបណ្តឹងទាមទារចុងក្រោយនេះ ត្រូវបានស្នើឡើងតាមរយៈទម្រង់ទីពីរនៃការអនុវត្តសំណងនេះ។

---

[4] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២/០២, **E457/6/2**, ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧, ផ្នែក ខ (២)។

[5] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២/០២, **E457/6/2**, ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧, ទំព័រ៣៧។

[6] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២/០២, **E457/6/2**, ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧, ទំព័រ៣៨-៤៤។

## ខ. វិធីសាស្ត្រ

5. សហមេធាវីនាំមុខបានអនុវត្តតាមគោលការណ៍សំខាន់ចំនួនបីនៅក្នុងការរៀបចំ និងអនុវត្តគម្រោងសំណងដែលអាចមានទាំងនេះ។ ទីមួយ និងជាចម្បង សហមេធាវីនាំមុខបានផ្អែកទៅលើសំណើ និងមតិយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីផ្ទាល់។ ទីពីរ សហមេធាវីនាំមុខបានអនុវត្តតាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខណៈដែលគម្រោងត្រូវផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី គម្រោងទាំងនោះក៏អាចផ្តល់ផលប្រយោជន៍ដល់សហគមន៍នៃជនរងគ្រោះដែលពុំមានតំណាងដែរ។ ចុងក្រោយ សហមេធាវីនាំមុខបានគិតដល់សច្ចារធារណ៍និរទោស និងផលប៉ះពាល់ដល់ការអនុវត្តគម្រោងមុនពេលចេញសាលដីកា[7]។ សហមេធាវីនាំមុខកត់សម្គាល់ថា "គម្រោងណាមួយ ប្រសិនបើរៀបចំរួចរាល់សម្រាប់ការអនុវត្ត មុនពេលបញ្ចប់កិច្ចដំណើរការនីតិវិធី នឹងត្រូវអនុវត្តជាសំណើ រហូតដល់មានការដាក់ទោសជាស្ថាពរ"[8]។

6. ទីមួយ បន្ទាប់ពីបានពិគ្រោះយោបល់យ៉ាងច្រើនជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី និងភាគីដែលពាក់ព័ន្ធ ដូចបានពិពណ៌នានៅក្នុងសារណារបញ្ចប់កិច្ចពិភាក្សាដេញដោល[9] សហមេធាវីនាំមុខបានរៀបចំបង្កើតគម្រោងសំណងដែលអាចមាន ដើម្បីជាការឆ្លើយតបទៅនឹងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានតាំងពីការដាក់បណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងឆ្នាំ២០០៧មក។ ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២/០២ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន

---

[7] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ការបង្ហាញពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន៨០ ស្ទួន (៤)), **E218/7**, ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២, កថាខណ្ឌ ២ ("ដោយពិចារណាទៅលើបញ្ហាប្រឈមនានាក្នុងការអនុវត្តសំណងដូចដែលបានលើកឡើងដោយសហមេធាវីនាំមុខអន្តរជាតិក្នុងកិច្ចប្រជុំរៀបចំសវនាការថ្មីៗកន្លងទៅនេះ អង្គជំនុំជម្រះសូមបញ្ជាក់ថា ការអនុវត្តវិធានទាំងនេះអាចនឹងចាប់ផ្តើម មុនពេលចេញសាលក្រមក្នុងសំណុំរឿង០០២/០១។ ការធ្វើបែបនេះគឺស្របទៅនឹងគោលបំណងនៃវិធាន ២៣ *ស្ទួនបួន* (៣) (ខ) នៃវិធានផ្ទៃក្នុង ដែលជំរុញការអនុវត្តសំណងប្រកបដោយអត្ថន័យក្នុងពេលវេលាដ៏សមស្រប ដោយមានជំនួយពីមូលនិធិម្ចាស់ជំនួយ និងកិច្ចសហការពីខាងក្រៅ។ លើសពីនេះទៀត សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអង្គភាពគាំពារជនរងគ្រោះ ត្រូវស្នើឲ្យកំណត់អំពីមូលដ្ឋានមូលនិធិអាទិភាពឲ្យបានឆាប់ ដើម្បីគាំទ្រគម្រោងទាំងនេះ ដែលត្រូវបានស្នើសុំជាសំណង")។

[8] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២/០២, **E457/6/2**, ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧, ទំព័រ៣៨-៤៤។

[9] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២/០២, **E457/6/2**, ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧, ទំព័រ១៨-១៩, ទំព័រ៤៥-៤៨។

១.២៦៥ នាក់ ត្រូវបានពិគ្រោះយោបល់ដើម្បីទទួលបានមតិទស្សនៈរបស់ពួកគាត់អំពីការរៀបចំបង្កើតគម្រោងសំណងសម្រាប់ជាប្រយោជន៍របស់ពួកគាត់នៅក្នុងវេទិកាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរៀបចំឡើងដោយអង្គភាពគាំពារជនរងគ្រោះ។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦០៩ នាក់ ត្រូវបានពិគ្រោះយោបល់នៅក្នុងកិច្ចពិគ្រោះយោបល់ស្តីពីសំណងដោយសហមេធាវីនាំមុខ និង អង្គភាពគាំពារជនរងគ្រោះ និងវេទិកាចែករំលែកព័ត៌មាន និងកិច្ចពិគ្រោះយោបល់នានាស្តីពីកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២[10]។ ដៃគូអនុវត្តក៏ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងវេទិកាទាំងនេះមួយចំនួនដែរ ដើម្បីបង្ហាញពីគម្រោងរបស់ខ្លួន និងសាកសួរពីការយល់ឃើញរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានវត្តមាននៅទីនោះ។ កិច្ចពិគ្រោះយោបល់ទាំងនេះត្រូវបញ្ជាក់នៅក្នុងសេចក្តីពិពណ៌នាអំពីគម្រោង នៅចំណុចផ្នែកផ្សេងៗនៃបណ្តឹងទាមទារចុងក្រោយនេះ។ កិច្ចពិគ្រោះយោបល់ដែលបានពិពណ៌នាខាងលើ និងផ្នែកផ្សេងៗទៀតនៃបណ្តឹងទាមទារចុងក្រោយ ត្រូវបានធ្វើឡើងបន្ថែមពីលើកិច្ចពិគ្រោះយោបល់ដែលបានធ្វើឡើងរវាងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងកូនក្តីម្នាក់ៗរបស់ពួកគាត់។

7. ទីពីរ សហមេធាវីនាំមុខបានអនុវត្តតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាសំណងជាសមូហភាព និងផ្លូវចិត្ត ជាសំខាន់ត្រូវផ្តល់ប្រយោជន៍ដល់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីដែលរួមបញ្ចូលគ្នា "ប៉ុន្តែវាអាចផ្តល់ផលប្រយោជន៍រួមផងដែរដល់ជនរងគ្រោះជាច្រើនផ្សេងទៀតដែលពុំមានតំណាង ដែលអ្នកទាំងអស់នោះបានទទួលរងព្យសនកម្មដោយសារតែការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលតុលាការរកឃើញថាជនជាប់មានពិរុទ្ធ"[11]។ សហមេធាវីនាំមុខចាត់ទុកផលប្រយោជន៍ដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលបានពីគម្រោងដែលអាចមានទាំងនេះថាជាកត្តា សំខាន់នៅក្នុងការបែងចែករវាងការអនុវត្តសំណងដែលអាចមានរបស់ អ.វ.ត.ក និងគម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ។

[10] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២/០២, ឧបសម្ព័ន្ធ ខ៖ វេទិកា និងកិច្ចពិគ្រោះយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២/០២, **E457/6/2.2.3**, ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧។

[11] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, **E313**, កថាខណ្ឌ ១១១៤, ជើងទំព័រ ៣២១០។

8. ទីបី សហមេធាវីនាំមុខក៏បានដឹងថា ជារឿយៗ ខ្លឹមសារនៃគម្រោងទាំងនេះ បង្ហាញ និងពិភាក្សាអំពីព្រឹត្តិការណ៍នានាដែលជាកម្មវត្ថុនៃកិច្ចដំណើរការនីតិវិធីដែលកំពុងដំណើរការ ហើយការពិភាក្សារបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសាលាក្រមសំណុំរឿង ០០២/០១ ដែលមានការកត់សម្គាល់ថា "ការសម្រេចអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ និងការកំណត់អំពីអង្គហេតុ គឺជាបុព្វសិទ្ធិតែមួយគត់របស់ អ.វ.ត.ក ដោយត្រូវផ្អែកលើការវាយតម្លៃពីភាពជឿជាក់បានរបស់សាក្សី និងដើមបណ្តឹង"[12]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានណែនាំឱ្យភ្ជាប់សេចក្តីបដិសេធទៅនឹងជំពូកមួយក្នុងសៀវភៅអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ[13]។ កន្លងមក សហមេធាវីនាំមុខបានប្រឹងប្រែងធានាថា "ខ្លឹមសារនៃគម្រោងទាំងនេះត្រូវបានរៀបចំដោយមាន ការពិចារណាអំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការសន្មតថាគ្មានទោស គឺថាបញ្ហា ប្រធានបទត្រូវបានដកចេញពីបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងស្របជាមួយឧក្រិដ្ឋកម្មដែលជនជាប់ចោទកំពុងត្រូវបានជំនុំជម្រះក្នុងសំណុំរឿង០០២/០២"[14]។

9. ស្រដៀងគ្នានឹងលិខិតដែលបានបញ្ជូនទៅកាន់ដៃគូគម្រោង បន្ទាប់ពីការចេញសាលដីកាសំណុំរឿង ០០២/០១ រួចមក ដែលស្នើឱ្យដៃគូគម្រោងធ្វើបច្ចុប្បន្នភាពសម្ភារៈឯកសារគម្រោង ឱ្យស្របនឹងសាលដីកា ជាពិសេសទាក់ទងនឹងទួលពោធិ៍ជ្រៃ[15] សហមេធាវីនាំមុខបានបញ្ជូនលិខិតទៅកាន់ដៃគូគម្រោង ដែលមានស្ថានភាពស្រដៀងគ្នានៅក្នុងសំណុំរឿងនេះ[16]។ សហមេធាវីនាំមុខក៏បាន

---

[12] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, **E313**, កថាខណ្ឌ ១១៥៧។

[13] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, **E313**, កថាខណ្ឌ ១១៥៧, ជើងទំព័រ ៣២៩៦។

[14] សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង ០០២/០២, **E352/2.1**, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ ៥។

[15] សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការអនុវត្តសំណងតាមផ្លូវតុលាការសម្រាប់សំណុំរឿង០០២/០១, **E218/7/9**, ថ្ងៃទី ១ ខែមីនា ឆ្នាំ ២០១៧, កថាខណ្ឌ ១៤, ១៩ និងឧបសម្ព័ន្ធ២៖ លិខិតពី សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, គម្រោងសំណងតាមផ្លូវតុលាការសំណុំរឿង០០២/០១,*ការតាំងពិពណ៌អចិន្ត្រៃយ៍អំពីការផ្លាស់ទីដោយបង្ខំនៅក្នុងសារៈមន្ទីរខេត្តចំនួនប្រាំ និងជំពូកបន្ថែមស្តីពីការផ្លាស់ទីលំនៅដោយបង្ខំនៅក្នុងសៀវភៅណែនាំសម្រាប់ គ្រូបង្រៀន៖ ការបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)* (ដាក់បញ្ចូលទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ) ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦, **E218/7/9.1.2**។

[16] ឧបសម្ព័ន្ធ ១.៨៖ គម្រោង App-Learning on Khmer Rouge History, លិខិតពីសហមេធាវីនាំមុខ ទៅកាន់មជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា ទាក់ទងនឹងអំណះអំណាង (Disclaimer)។ ឧបសម្ព័ន្ធ ១៤.៦, វេទិកាអប់រំជាសាធារណៈ និង *បណ្តឹងទាមទារចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណង នៅក្នុងសំណុំរឿង ០០២/០២ ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់*

រៀបចំរួចរាល់ក្នុងការបញ្ជូនលិខិតបន្ថែមទៀតទៅកាន់ដៃគូគម្រោង ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាលិខិតទាំងនោះគួរតែបញ្ជូនទាក់ទងនឹងខ្លឹមសារនៃគម្រោងផ្សេងទៀតដែលបានស្នើឡើង។

## គ. និដ្ឋភាពរួមអំពីសារៈណា និងសំណើទាក់ទងនឹងការអនុវត្តមូលនិធិ

10. អនុលោមតាមលក្ខខណ្ឌរបស់អង្គជំនុំជម្រះ[17] គម្រោងចំនួន ១២ បានទទួលមូលនិធិពីខាងក្រៅគ្រប់គ្រាន់ និងផ្តល់ប្រយោជន៍ប្រកបដោយអត្ថន័យដល់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះព្យសនកម្មដែលពួកគាត់បានទទួលរងដោយសារបទឧក្រិដ្ឋដែលបានចោទនៅក្នុងសំណុំរឿង០០២/០២។ ក្នុងនោះ គម្រោងចំនួន ១១ ត្រូវបានគាំទ្រដោយសហមេធាវីនាំមុខជាតិ និងអន្តរជាតិ និងត្រូវបានដាក់បង្ហាញនៅក្នុងផ្នែកទីពីរ។ គម្រោងមួយត្រូវបានគាំទ្រតែដោយសហមេធាវីនាំមុខអន្តរជាតិ និងត្រូវបានដាក់បង្ហាញនៅក្នុងផ្នែកទីបី។ គម្រោងចំនួនពីរត្រូវបានស្នើឡើងដោយអង្គភាពគាំពារជនរងគ្រោះ និងត្រូវបានពិពណ៌នានៅក្នុងផ្នែកទីបួន។

11. សហមេធាវីនាំមុខកត់សម្គាល់ថា ពុំមានការដាក់បញ្ចូលគ្រប់សំណើគម្រោងទាំងអស់នៅក្នុងបណ្តឹងទាមទារចុងក្រោយនេះទេ[18]។ សហមេធាវីនាំមុខបានពិចារណាអំពីភាពអាចអនុវត្តបាននៃសំណើគម្រោង ថាតើគម្រោងនឹងផ្តល់ផលប្រយោជន៍គ្រប់គ្រាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងប្រធានបទនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ ដែរឬទេ ថាតើគម្រោងមានភាពជាក់លាក់គ្រប់គ្រាន់ដែរឬទេ ថាតើគម្រោងដែលអាចមានទាំងនោះ មាន ឬអាចទទួលបានឯកសារដែលត្រូវការទាំងអស់ដែរឬទេ និងថាតើមានការព្រមព្រៀងគ្នារវាងសហមេធាវីនាំមុខ

---

ការតាំងពិពណ៌អចិន្ត្រៃយ៍អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ, លិខិតពីសហមេធាវីនាំមុខទៅកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាទាក់ទងនឹងអំណះអំណាង (Disclaimer)។ គម្រោងទាំងពីរនឹងត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយទៅដល់អ្នកចូលរួម និងអាចកំណត់បានថាមានលក្ខណៈអចិន្ត្រៃយ៍។

[17] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, **E313**, កថាខណ្ឌ ១១២២។

[18] សហមេធាវីនាំមុខ បានទទួលសំណើគម្រោងចំនួន១៤ ដែលពុំបានដាក់បញ្ចូលនៅក្នុងបណ្តឹងទាមទារចុងក្រោយ។

ក្នុងការពិគ្រោះយោបល់ជាមួយនឹងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងអង្គភាពគាំពារជនរងគ្រោះដែរឬទេ[19]។

12. វិធាន ២៣ ស្ទួនបួន (២) នៃវិធានផ្ទៃក្នុង ចែងថា ទាក់ទងនឹងគម្រោងនីមួយៗ គឺជា ការពិពណ៌នាអំពីសំណងដែលត្រូវទាមទារ និង "ទទ្ធីករណ៍សមហេតុផល ដូចជា ការលើកពីការខូចខាតដែលពួកគេទទួលរង និងក្នុងករណីដែលអាចអនុវត្តបាន បញ្ជាក់អំពីក្រុមដើមបណ្ដឹងរដ្ឋប្បវេណីក្នុងក្រុមរួមដែលពួកគេជាប់ពាក់ព័ន្ធ"។ ដូចបានលើកឡើងរួចមកហើយ សំណងទាំងអស់ត្រូវទាមទារដោយអនុលោមតាមវិធាន ២៣ ស្ទួនបួន (៣) (ខ) នៃវិធានផ្ទៃក្នុង[20]។

13. ដោយសារភាពយឺតយ៉ាវនៃការរៃអង្គាសមូលនិធិ អង្គភាពគាំពារជនរងគ្រោះបានស្នើពន្យារពេលកំណត់នៃការរៃអង្គាសមូលនិធិ រហូតដល់ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៧[21]។ ដូច្នេះ សហមេធាវីនាំមុខស្នើសុំលទ្ធភាពដាក់សារណាបន្ថែម ប្រសិនបើមានការធានាមូលនិធិសម្រាប់គម្រោងចំនួនបួន ដែលបានស្នើសុំក្នុងផ្នែកទីបួន និងគម្រោងចំនួនពីរនៅក្នុងផ្នែកទីប្រាំ។ ប្រសិនបើ សំណើសុំការពន្យារពេលត្រូវបានអនុញ្ញាត ហើយប្រសិនបើពុំទទួលបានឯកសារបង្ហាញអំពីការធានាមូលនិធិពេញលេញនៅពេលនេះទេ សំណើនេះគួរត្រូវបានចាត់ទុកថាដកចេញ។ ស្រដៀងគ្នានេះដែរ ប្រសិនបើសំណើសុំការពន្យារពេលពុំទទួលបានការអនុញ្ញាតទេនោះ សហមេធាវីនាំមុខនឹងដកគម្រោងទាំងនេះចេញពីការស្នើសុំឲ្យពិចារណា។

14. ឧបសម្ព័ន្ធសម្ងាត់ដែលភ្ជាប់ជាមួយគម្រោងនីមួយៗ មានលិខិតទំនាក់ទំនងរវាងដៃគូគម្រោង សហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ ទិដ្ឋភាពរួមអំពីគម្រោងសំណង សេចក្ដីពិពណ៌នាអំពី

---

[19] គម្រោងការអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្ដឹងរដ្ឋប្បវេណីជាជនជាតិភាគតិច គឺជាគម្រោងតែមួយគត់ដែលពុំទទួលបានការឯកភាពជាឯកច្ឆ័ន្ទ។ គម្រោងនេះត្រូវបានដាក់បញ្ចូលនៅក្នុងសំណើរបស់សហមេធាវីនាំមុខអន្តរជាតិ នៅក្នុងផ្នែកទី២។ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ២ នាក់ បានចូលរួមក្នុងការរៀបចំបង្កើតគម្រោង និងតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដែលទទួលរងផលប៉ះពាល់។

[20] របាយការណ៍បណ្ដោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីសំណងនៅក្នុងសំណុំរឿង០០២/០២ និងសំណើពាក់ព័ន្ធ, **E352**, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ១៧។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង០០២/០២, E352/2/1, ថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ៤។

[21] ឧបសម្ព័ន្ធទី១៥៖ លិខិតពីអង្គភាពគាំពារជនរងគ្រោះ។

ដៃគូអនុវត្តគម្រោង សេចក្ដីលម្អិត និងថវិកានៃគម្រោង ភស្តុតាងនៃមូលនិធិដែលទទួលបាន កិច្ចព្រមព្រៀងដែលពាក់ព័ន្ធ និងការអនុញ្ញាតពីភាគីទីបី និងរបាយការណ៍ពីការអនុវត្តពីដៃគូគម្រោង ប្រសិនបើមាន[22]។

## II. គម្រោងដែលបានទទួលការឧបត្ថម្ភថវិកាពេញលេញ និងគាំទ្រដោយសហមេធាវីនាំមុខជាតិ និងអន្តរជាតិ

### ក. ការធានាអំពីការមិនកើតឡើងជាថ្មី

15. ជាវិធានការសំណងមួយ ការធានាអំពីការមិនកើតឡើងជាថ្មីនៃបទឧក្រិដ្ឋទាំងនោះ ជំរុញឱ្យមានយន្តការសម្រាប់ការទប់ស្កាត់ និងការពិនិត្យមើលជម្លោះក្នុងសង្គម និងជំរុញនូវដំណោះស្រាយដោយសន្តិវិធីរបស់ពួកគេ[23]។ ដើមបណ្ដឹងរដ្ឋប្បវេណីតែងតែចាត់ទុកការជជែកគ្នាដោយមានការចូលរួមពីមនុស្សវ័យខុសៗគ្នា រួមមានតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងគម្រោងសិល្បៈ ថាជាវិធីមួយដើម្បីទប់ស្កាត់កុំឱ្យមានការកើតឡើងជាថ្មីនៃអំពើសាហាវព្រៃផ្សៃក្នុងទ្រង់ទ្រាយធំនៅកម្ពុជា។ ដូចបានពិពណ៌នានៅក្នុងផ្នែកព្យសនកម្ម បន្ទាប់ពីជំពូកនីមួយៗក្នុងផ្នែកទីបួននៃសារណាបញ្ចប់ការពិភាក្សាដេញដោល[24] និងនៅក្នុងសំណួររបស់ពួកគាត់ទៅកាន់ជនជាប់ចោទ[25] ដើមបណ្ដឹងរដ្ឋ

[22] ឯកសារទាំងអស់ ដែលបានទទួល ត្រូវបានបំពេញ និង/ឬត្រូវបានដាក់ដោយដៃគូគម្រោង។

[23] គោលការណ៍ និងគោលការណ៍ណែនាំជាមូលដ្ឋានស្ដីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភដ៏កម្រោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ, សេចក្ដីសម្រេចលេខ ៦០/១៤៧,មហាសន្និបាតអង្គការសហប្រជាជាតិ, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥, មាត្រា២៣។

[24] *សូមមើល ឧទាហរណ៍* ប្រតិចារឹកនៃការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សូវីដា, ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥, **E1/308.1, [**កែតម្រូវ១**]** ,ទំព័រ៩០, បន្ទាត់ទី២៥ ដល់ទំព័រ៩២ បន្ទាត់ទី២ (“**…**ឱ្យប្រជាជនកម្ពុជាជំនាន់ក្រោយយល់ដឹងពីការពិត, ដឹងពីប្រវត្តិសាស្ត្រដែលបានកើតឡើង...”)។ ប្រតិចារឹកនៃការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី រី ពៅ, ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០១៥, **E1/262.1, [**កែតម្រូវ១**]** ,ទំព័រ៧៤, បន្ទាត់ទី២០ ដល់ទំព័រ៧៥ បន្ទាត់ទី៤ (“បើនិយាយអំពីទុក្ខសោកក្នុងរបបប្រល័យពូជសាសន៍នោះ បើខ្ញុំនិយាយទៅ ខ្ញុំមិនចង់បានអ្វីដែលគួរឱ្យសម្រាប់ខ្លួនខ្ញុំទេ។ ប៉ុន្តែខ្ញុំចង់ថា ខ្ញុំសព្វថ្ងៃនេះ វាមានវិប្បដិសារីដល់ឪពុកម្ដាយខ្ញុំ ដល់ប្អូនរបស់ខ្ញុំ ដល់បងប្អូនដែលបានទទួលរងទុក្ខ ដែលពួកខ្មែរក្រហមធ្វើទារុណកម្មកាប់សម្លាប់សហាវព្រៃផ្សៃ ដោយអំពើអយុត្តិធម៌ធ្វើប្រតិកម្មមកលើក្រុមគ្រួសាររបស់ខ្ញុំនេះ។ អញ្ជឹងខ្ញុំគ្រាន់ថា អ្វីទាំងឡាយសូមឱ្យខាងអង្គការសហប្រជាជាតិ ព្រមទាំងតុលាការសាលាក្ដីខ្មែរក្រហមហ្នឹង មេត្តាជួយធ្វើយ៉ាងណាកុំឱ្យមានអារបបឃោឃៅព្រៃផ្សៃអញ្ចឹងវិលត្រឡប់មកវិញបានទៀត ហើយក៏សំណូមពរឱ្យខាងផ្នែកតុលាការហ្នឹង ជួយធ្វើការ *បណ្ដឹងទាមទារចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់សំណង នៅក្នុងសំណុំរឿង ០០២/០២ ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់*

ប្បវេណីបានលើកឡើងជាច្រើនដងអំពីបំណងប្រាថ្នាកុំឲ្យបទពិសោធន៍របស់ពួកគាត់កើតឡើងជាថ្មីនៅពេលអនាគត តាមរយៈការអប់រំមនុស្សជំនាន់ក្រោយអំពីអតីតកាល។

16. សហមេធាវីនាំមុខ យល់ឃើញថា គម្រោងខាងក្រោមមានផលប៉ះពាល់ទៅលើវិធានការសំណងនៃការធានាអំពីការមិនកើតឡើងជាថ្មី និងផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះព្យសនកម្មដែលបានទទួលរងដោយសារបទឧក្រិដ្ឋដែលបានចោទក្នុងវិសាលភាពនៃសំណុំរឿង០០២/០២។ ដូច្នេះ សហមេធាវីនាំមុខសុំស្នើឲ្យអង្គជំនុំជម្រះអនុម័តគម្រោងទាំងនេះថាជាការផ្តល់សំណងរបស់តុលាការដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០២។

---

វិនិច្ឆ័យកាត់ទោស កាត់ទោសពួកមេខ្លោងរបស់ខ្មែរក្រហមហ្នឹងឲ្យសមនឹងកំហុសឆ្គងដែលខ្លួនបានប្រព្រឹត្តទៅលើប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស។”)

[25] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហមេធាវីនាំមុខក្នុងសំណុំរឿង០០២/០២, ឧបសម្ព័ន្ធ ង, E457/6/2.2.6, ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧។ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សូវីដា, ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥, **E1/308.1,** [កែតម្រូវ១] ,ទំព័រ៨៨, បន្ទាត់ទី១ ដល់ទី៣ (“សូមប្រាប់យើងនូវការពិត ប្រាប់យើងអំពីអ្វីដែលបានកើតឡើង ហើយនេះជាផ្នែកនៃប្រវត្តិសាស្ត្រកម្ពុជា ដើម្បីឲ្យមនុស្សជំនាន់អាចស្វែងយល់”)។ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥, **E1/282.1,** [កែតម្រូវ១] ,ទំព័រ១១៨, បន្ទាត់ទី១៥ ដល់ទី២០ (“ទោះបីរូបខ្ញុំឡើងមកតុលាការនេះ ក៏គ្មាននឹងផលប្រយោជន៍បុគ្គលខ្ញុំផ្ទាល់ក៏អត់មានទេ មានដើម្បីក្មេងស្រករក្រោយ និងអ្នកស្លាប់ទៅចែកឋានទៅបានស្លាប់ជាតិក្រោយៗ កុំឲ្យប៉ះពាល់សង្គមដែលមិនដែលឃើញអត់ដែលឃើញ។ បានថានិយាយមិនចង់ឃើញ”)។ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន, ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦, **E1/488.1,** ,ទំព័រ៨១, បន្ទាត់ទី២៣ ដល់ទំព័រ៨៤, បន្ទាត់ទី២ (“អញ្ចឹងខ្ញុំសូមផ្តាំផ្ញើដល់បងប្អូនទាំងអស់ក។ចង់បានមេដឹកនាំដូចរបបខ្មែរក្រហមអី វេទនាណាស់ ប្រជាពលរដ្ឋ ប្រើធ្វើការគ្មានពេលសម្រាក មិនឲ្យហូបចុក បំបែកបំបាក់បងប្អូន។ អញ្ចឹងកុំឲ្យមានជីវិតបងប្អូនដូចខ្ញុំតទៅទៀត”)។ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់, ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦, **E1/483.1,** ,ទំព័រ៦៩, បន្ទាត់ទី១៧ ដល់បន្ទាត់ទី២២ (“ខ្ញុំសូមទាមទារសំណងដូចជា វត្តអារាម សាលារៀន ឲ្យកូនក្មេងសាក្រោយដឹងអំពីអ្វីដែលបានកើតឡើង។ ហើយខ្ញុំមិនចង់ឲ្យរបបផ្តាច់ការនេះវិលត្រឡប់មកក្នុងប្រទេសវិញ”)។ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល, ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦, **E1/464.1,** ,ទំព័រ៦២, បន្ទាត់ទី២០ ដល់ទំព័រ២១ (“សូមលោកប្រធាន ធ្វើយ៉ាងម៉េច កុំឲ្យរបបនេះកើតឡើងតទៅទៀត”)។ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន, ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៥, **E1/344.1,** [កែតម្រូវ២] ,ទំព័រ៦៤, បន្ទាត់ទី៥ ដល់ទី១០ (“ខ្ញុំមិនអាចសម្តែងចេញអ្វីៗទាំងអស់ទេ។ ប៉ុន្តែខ្ញុំបានប្រាប់តុលាការ និងខ្ញុំបានប្រាប់នូវអ្វីដែលខ្ញុំបានឆ្លងកាត់ក្នុងរបបនោះ។ ខ្ញុំសូមអំពាវនាវដល់តុលាការនេះ តុលាការជាតិ និងតុលាការអន្តរជាតិ ព្រមទាំងអង្គការសហប្រជាជាតិ ធ្វើយ៉ាងណាកុំឲ្យរបបនេះវាត្រឡប់មកកាន់កាប់ប្រទេសម្តងទៀត”)។

### (១) គម្រោង App-Learning on Khmer Rouge History

17. មជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា សហការជាមួយសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានរៀបចំបង្កើត និងកំពុងអនុវត្ត "គម្រោង App-Learning on Khmer Rouge History" ជាសំណើមួយអំពីសំណងរបស់តុលាការ[26]។ គម្រោងនេះបានចងក្រងព័ត៌មានដែលត្រឹមត្រូវ និងរៀបចំព័ត៌មានឲ្យបានត្រឹមត្រូវអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីធ្វើឲ្យព័ត៌មាននេះអាចមើលបានតាមរយៈកម្មវិធីប្រព័ន្ធផ្សព្វផ្សាយចម្រុះប្រកបដោយភាពច្នៃប្រឌិតដែលបញ្ចូលសម្ភារៈឯកសារសោតទស្សន៍ដែលបន្សល់ទុកពីសម័យខ្មែរក្រហម និងរឿងរ៉ាវរបស់ដើមបណ្ដឹងរដ្ឋប្បវេណី[27]។ កម្មវិធីនេះនឹងត្រូវផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅលើប្រព័ន្ធអ៊ីនធឺណែត និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ដោយមិនគិតថ្លៃ និងទទួលបានការអនុញ្ញាតជាផ្លូវការពីក្រសួងអប់រំ យុវជន និងកីឡា ដូច្នេះអាចថា ព័ត៌មានទាំងអស់នេះត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅតាមសាលារៀនទូទាំងប្រទេស។ គម្រោងនេះមានរយៈពេល ២៨ ខែ[28]។ ជំពូកផ្សេងៗនៃកម្មវិធី

---

[26] ឧបសម្ព័ន្ធទី ១៖ គម្រោង App-Learning on Khmer Rouge History។ *សូមមើលផងដែរ,* របាយការណ៍បណ្ដោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីសំណងនៅក្នុងសំណុំរឿង០០២/០២ និងសំណើពាក់ព័ន្ធ, **E352**, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ២១ និងឧបសម្ព័ន្ធសម្ងាត់ទី១ (គម្រោងទី១០), **E352. 2,** សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្ត ក្នុងសំណុំរឿង០០២/០២, **E352/2/1**, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ១៦-១៨ និងគម្រោងជាអាទិភាព (គម្រោងទី១), **E352/2/1.2.3**។

[27] ឧបសម្ព័ន្ធទី ១៖ គម្រោង App-Learning on Khmer Rouge History។ ទិដ្ឋភាពអំពីគម្រោងសំណង។ ឧបសម្ព័ន្ធ ១.៤៖ គម្រោង App-Learning on Khmer Rouge History។ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, កិច្ចព្រមព្រៀងនៃការផ្ដល់ជំនួយគាំទ្ររបស់អង្គការ UNOPS (រួមបញ្ចូលព័ត៌មានលម្អិតអំពីគម្រោង និងថវិកាគម្រោង)។ ឧបសម្ព័ន្ធ ១.៦៖ គម្រោង App-Learning on Khmer Rouge History, តារាងមាតិកានៃគម្រោងកម្មវិធី App។ ប្រធានបទសំខាន់ៗនៃកម្មវិធីក្របដណ្ដប់៖ ការឡើងកាន់អំណាចរបស់ខ្មែរក្រហម, ការដួលរលំនៃទីក្រុងភ្នំពេញ, ជីវភាពប្រចាំថ្ងៃក្រោមការដឹកនាំរបស់ខ្មែរក្រហម (រួមមាន ជីវិតនៅក្នុងសហករណ៍ និងការបះបោលរបស់ជនជាតិចាម), គោលនយោបាយខ្មែរក្រហម និងមនោគមន៍វិជ្ជា, រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងប្រព័ន្ធសន្តិសុខ (រួមទាំងមន្ទីរសន្តិសុខ ស២១), វិថីឆ្ពោះទៅរកយុត្តិធម៌។

[28] ឧបសម្ព័ន្ធទី ១.២៖ គម្រោង App-Learning on Khmer Rouge History។ ទិដ្ឋភាពអំពីគម្រោងសំណង។ ឧបសម្ព័ន្ធ ១.៤៖ គម្រោង App-Learning on Khmer Rouge History។ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, កិច្ចព្រមព្រៀងនៃការផ្ដល់ជំនួយគាំទ្ររបស់អង្គការ UNOPS (រួមបញ្ចូលព័ត៌មានលម្អិតអំពីគម្រោង និងថវិកាគម្រោង)។ ឧបសម្ព័ន្ធ ១.៧៖ គម្រោង App-Learning on Khmer Rouge History, អនុស្សរណៈរវាងក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា ស្ដីពីគម្រោង App-Learning on Khmer Rouge History។

ផ្សព្វផ្សាយនេះត្រូវបានបង្ហាញដល់សាធារណជនកាលពីថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧ ហើយ កម្មវិធីនេះនឹងដាក់ឲ្យប្រើប្រាស់នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧ នៅក្នុងពិធីដាក់ឲ្យប្រើប្រាស់ជាផ្លូវការជាសាធារណៈមួយ។

18. គម្រោងនេះផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការអប់រំយុវជនកម្ពុជា និង សាធារណជន អំពីបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងប្រវត្តិសាស្ត្រខ្មែរក្រហម។ គម្រោងនេះលើកទឹកចិត្តថែមទៀតចំពោះការសន្ទនាអន្តរជំនាន់រវាងអ្នកនៅរស់រានមានជីវិត និង យុវជន ដើម្បីទប់ស្កាត់កុំឲ្យបទឧក្រិដ្ឋបែបនោះកើតឡើងទៀតនៅក្នុងប្រទេសកម្ពុជា។ តាមរយៈការអប់រំ និងកិច្ចសន្ទនា គម្រោងនេះក៏ផ្តល់ប្រយោជន៍ដល់ជនរងគ្រោះដែលពុំមានតំណាងជាច្រើននាក់។ គម្រោងនេះបានធ្វើកិច្ចសម្ភាសន៍ជាមួយដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៧ នាក់អំពីបទពិសោធន៍របស់ពួកគាត់ទាក់ទងនឹងបទឧក្រិដ្ឋនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ ដែលត្រូវដាក់បញ្ចូលនៅក្នុងឯកសារគម្រោង។ កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៦ តំណាងមកពីមជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា បានចូលរួមក្នុងវេទិកាមួយនៅទីក្រុងភ្នំពេញ និងបានបង្ហាញគម្រោងនេះដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១១០ នាក់ និងទទួលបានមតិយោបល់ពីពួកគាត់។ កម្មវិធីនេះត្រូវបានបង្ហាញដល់សាធារណជននៅមជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណានៅភ្នំពេញ កាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦ និងមានវត្តមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១២ នាក់។ កាលពីថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៦ មជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា បានបង្ហាញគម្រោងនេះដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៣០ នាក់ នៅវេទិកាដើមបណ្តឹងរដ្ឋប្បវេណីមួយទៀត ដើម្បីប្រមូលមតិយោបល់របស់ពួកគេ។ កម្មវិធីនេះ ត្រូវបានបង្ហាញដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៣៦ នាក់នៅកិច្ចពិគ្រោះយោបល់ស្តីពីសំណង ដែលរៀបចំឡើងដោយសហមេធាវីនាំមុខ/អង្គភាពគាំពារជនរងគ្រោះ និងវេទិកាចែករំលែកព័ត៌មានដែលបានធ្វើឡើងនៅកំពង់ចាម កាលពីថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១៧។

19. គម្រោងនេះបានទទួលការឧបត្ថម្ភថវិកាទាំងស្រុងពីសហភាពអឺរ៉ុប តាមរយៈការិយាល័យ UNOPS និងពីមូលនិធិ Rei[29]។

### (២) ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ

20. មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានបង្កើត និងកំពុងអនុវត្តសំណើ "*គម្រោងអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ*"[30]។ ដោយមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី គម្រោងនេះនឹងធ្វើការបណ្តុះបណ្តាលគ្រូបង្រៀនចំនួនពីរវគ្គ និងបណ្តុះបណ្តាលសាស្ត្រាចារ្យមហាវិទ្យាល័យចំនួនមួយវគ្គ និងរៀបចំវេទិកាតាមថ្នាក់រៀនចំនួន ១៥លើក ដោយមានការធ្វើបទបង្ហាញ ការធ្វើសកម្មភាពជាក្រុម និងការពិភាក្សា។ ការអនុវត្តគម្រោងនេះមានរយៈពេល ៣៦ខែ[31]។ ជាផ្នែកមួយនៃការអនុវត្តគម្រោងនេះ ការបណ្តុះបណ្តាលគ្រូបង្រៀននៅឃុំមួយលើកត្រូវបានធ្វើឡើងរយៈពេល ៥ ថ្ងៃ ដោយចាប់ផ្តើមពីថ្ងៃទី៣ ខែមេសា ឆ្នាំ ២០១៧។ កម្មវិធីនេះមានអ្នកចូលរួមជាង ១០០ នាក់ មកពីខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី។ ការបណ្តុះបណ្តាល និងកម្មវិធីសិក្សានៃគម្រោងនេះ

---

[29] ឧបសម្ព័ន្ធទី ១.៤៖ គម្រោង App-Learning on Khmer Rouge History។ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, កិច្ចព្រមព្រៀងនៃកាផ្តល់ជំនួយគាំទ្ររបស់អង្គការ UNOPS (រួមបញ្ចូលព័ត៌មានលម្អិតអំពីគម្រោង និងថវិកាគម្រោង)។ ឧបសម្ព័ន្ធ ១.៥៖ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, ការកែសម្រួល និងការបញ្ជាក់ឡើងវិញលើអនុស្សរណៈរវាងមូលនិធិ Rei និង មជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា ស្តីពីគម្រោង App-Learning on Khmer Rouge History។

[30] ឧបសម្ព័ន្ធ២៖ ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ។ *សូមមើលផងដែរ,* សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង០០២/០២, E352/2/1, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ ៩-១២ និងឧបសម្ព័ន្ធ ៣៖ គម្រោងដែលត្រូវបានចាត់ជាអាទិភាព (គម្រោងទី២), E352/2/1.2.3។

[31] ឧបសម្ព័ន្ធ ២៖ ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ, ទិដ្ឋភាពរួមអំពីគម្រោង។

ត្រូវបានក្រសួងអប់រំ យុវជន និងកីឡា ឯកភាពសម្រាប់ប្រើប្រាស់តាមសាលារៀន និងសាកលវិទ្យាល័យនៅកម្ពុជា [32]។

21. គម្រោងនេះផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការអប់រំយុវជនកម្ពុជាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីទប់ស្កាត់ការវិលត្រឡប់មកវិញនៃឧក្រិដ្ឋកម្មទាំងនេះ។ កាលពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៦ មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្សព្វផ្សាយគម្រោងដែលបានស្នើឡើងនេះនៅភ្នំពេញ នៅក្នុងពិធីមួយដែលមានដើមបណ្តឹងរដ្ឋប្បវេណីចូលរួមចំនួន ៤ នាក់។ កាលពីថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ តំណាងមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា បានចូលរួមកិច្ចពិគ្រោះយោបល់ស្តីពីសំណងដោយសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ និងវេទិកាចែករំលែកព័ត៌មាននៅភ្នំពេញ និងបង្ហាញគម្រោងនេះដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៤៧ នាក់ និងទទួលបានមតិយោបល់របស់ពួកគាត់។

22. គម្រោងនេះបានទទួលការឧបត្ថម្ភថវិកាទាំងស្រុងពីសហភាពអឺរ៉ុប តាមរយៈការិយាល័យ UNOPS [33]។

### (៣) គម្រោងអណ្តើក៖ គម្រោងអន្តរព័ត៌មានប្រកបដោយភាពច្នៃប្រឌិត ដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រ និងភាពក្លាហានរបស់ពលរដ្ឋនៅកម្ពុជា

23. សមាគមវប្បធម៌អាល្លឺម៉ង់កម្ពុជា និងអង្គការ Khmer Art Action ដោយមានការគាំទ្រពីសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានបង្កើត និងកំពុងអនុវត្ត "*គម្រោងអណ្តើក៖ គម្រោងអន្តរព័ត៌មានប្រកបដោយភាពច្នៃប្រឌិត ដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រ និងភាពក្លាហានរបស់ពលរដ្ឋនៅកម្ពុជា*" ដែលជាគម្រោងសំណងតុលាការដែលបានស្នើឡើងក្នុង

[32] ឧបសម្ព័ន្ធ ២.៥៖ ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ។ អនុស្សរណៈរវាងក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា។

[33] ឧបសម្ព័ន្ធ ២.៤៖ ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ។ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, កិច្ចព្រមព្រៀងនៃការផ្តល់ជំនួយគាំទ្ររបស់អង្គការ UNOPS។

សំណុំរឿង០០២/០២[34]។ អង្គការយុវសន្តិភាពក៏បានចូលរួមនៅក្នុងផ្នែកផ្សេងៗនៃគម្រោងនៅក្នុងដំណាក់កាលដំបូងនៃគម្រោងនេះ។[35] គម្រោងនេះដាក់បញ្ចូលសកម្មភាពវប្បធម៌ពហុព័ត៌មាន និងអប់រំក្នុងអំឡុងសិក្ខាសាលានានាជាមួយសិស្សវិទ្យាល័យ និងនិស្សិតសាកលវិទ្យាល័យ។ គម្រោងនេះក៏ដាក់បញ្ចូលការបញ្ចាំងខ្សែភាពយន្ត ការតាំងពិពណ៌រូបថត និងការសន្ទនាអន្តរជំនាន់ ដែលផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីចែករំលែកបទពិសោធន៍របស់ពួកគាត់ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យជាមួយមនុស្សជំនាន់ក្រោយ[36]។ គម្រោងនេះបានចាប់ផ្តើមសកម្មភាពក្នុងឆ្នាំ ២០១៥ និងបន្តរហូតដល់ចុងឆ្នាំ ២០១៧ ដោយមានការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា [37]។ រហូតដល់ចុងឆ្នាំ ២០១៧ ព្រឹត្តិការណ៍ទូទាំងប្រទេសចំនួន ៣៤ នឹងត្រូវបានធ្វើឡើងនៅតាមវិទ្យាល័យ សាកលវិទ្យាល័យ និងនៅមជ្ឈមណ្ឌល Meta House នៅភ្នំពេញ [38]។ ការតាំងពិពណ៌រូបភាព ត្រូវបានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឯកភាពឲ្យដាក់បញ្ចាំងនៅទួលស្លែង[39]។

24. គម្រោងនេះផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការអប់រំឲ្យមនុស្សជំនាន់ក្រោយអំពីបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងការបង្កើតវេទិកាសន្ទនាអន្តរជំនាន់ ក្រោយមានការសម្តែងនីមួយៗ។ គម្រោងនេះបានរៀបចំកិច្ចពិគ្រោះយោបល់ចំនួន ៧ លើក ជាមួយដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៦៩ នាក់ នៅពេលដែលមាតិកានៃការសម្តែង ត្រូវបានរៀបចំឡើង។

---

[34] ឧបសម្ព័ន្ធ ៣៖ គម្រោងអណ្តើក៖ គម្រោងអន្តរព័ត៌មានប្រកបដោយភាពច្នៃប្រឌិត ដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រ និងភាពក្លាហានរបស់ពលរដ្ឋ។ *សូមមើលផងដែរ,* របាយការណ៍បណ្តោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណងនៅក្នុងសំណុំរឿង០០២/០២ និងសំណើពាក់ព័ន្ធ, **E352**, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ២១ និងឧបសម្ព័ន្ធសម្ងាត់ទី១ (គម្រោងទី១១), **E352.2** ។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង០០២/០២, **E352/2/1**, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ២២-២៥ និងឧបសម្ព័ន្ធ ៣៖ គម្រោងត្រូវបានចាត់ជាអាទិភាព (គម្រោងទី៣), **E352/2/1.2.3**។

[35] ឧបសម្ព័ន្ធ ៣.២៖ គម្រោងអណ្តើក, ទិដ្ឋភាពរួមអំពីគម្រោងសំណង។ ឧបសម្ព័ន្ធ ៤៖ គម្រោងអណ្តើក, កិច្ចព្រមព្រៀងនៃការផ្តល់ជំនួយគាំទ្ររបស់អង្គការ UNOPS។

[36] *ដូចជើងទំព័រខាងលើ។*

[37] ឧបសម្ព័ន្ធ ៤៖ គម្រោងអណ្តើក, អនុស្សរណៈរវាងសមាគមវប្បធម៌កម្ពុជាសហព័ន្ធអាល្លឺម៉ង់ និងក្រសួងអប់រំ យុវជន និងកីឡា។

[38] ឧបសម្ព័ន្ធ ៤៖ គម្រោងអណ្តើក, របាយការណ៍នៃការអនុវត្ត។

[39] ឧបសម្ព័ន្ធ ៤៖ គម្រោងអណ្តើក, លិខិតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ស្តីពីការតាំងពិពណ៌នៅទួលស្លែង។

កម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សក៏បានធ្វើការពិគ្រោះយោបល់ទាក់ទងនឹងការរៀបចំ និងបង្កើតគម្រោងនេះ និងគម្រោងចំនួនពីរទៀត ដែលមានដើមបណ្ដឹងរដ្ឋប្បវេណី ៨ នាក់ចូលរួម។ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប្រហែល ១៥០ នាក់ និងសិស្សនិស្សិតចំនួនជាង ១០.០០០ នាក់ បានទស្សនាការសម្ដែង និងបានចូលរួមក្នុងការសន្ទនាក្រោយពេលសម្ដែងរួច។ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីររូប នឹងត្រូវបានអញ្ជើញទៅសាលារៀន និងសាកលវិទ្យាល័យនៅពេលមានការសម្ដែង។ ជាផ្នែកមួយនៃសកម្មភាពគម្រោង ការតាំងពិពណ៌ត្រូវបានធ្វើឡើងនៅសៀមរាប ដោយដាក់បង្ហាញរូបថតចំនួន ១០០សន្លឹករបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជាមួយនឹងសារសម្រាប់មនុស្សជំនាន់ក្រោយ ដែលមានការចូលរួមពីដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១០ នាក់[40]។

25. គម្រោងនេះត្រូវបានផ្ដល់ថវិកាទាំងស្រុងដោយ The Institut für Auslandsbeziehungen (ifa) នៃក្រសួងការបរទេសសហព័ន្ធអាល្លឺម៉ង់ តាមរយៈមូលនិធិ “zivik” និងសហភាពអឺរ៉ុប តាមរយៈការិយាល័យ UNOPS[41]។

## ខ. ការធានាអំពីការមិនកើតឡើងវិញជាថ្មី (គម្រោងផ្ដល់ប្រយោជន៍ដល់ក្រុមដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះជាក់លាក់)

26. គម្រោងចំនួនបីត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងព្យសនកម្មដែលក្រុមជាក់លាក់មួយចំនួនបានទទួលរងដោយសារតែបទឧក្រិដ្ឋនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២។ គម្រោងទាំងនេះបានព្យាយាមផ្ដល់ប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណីដែលរងការប៉ះពាល់ដោយសារការប្រព្រឹត្តទៅលើជនជាតិចាម[42] ជនជាតិវៀតណាម [43] និងដើមបណ្ដឹងរដ្ឋប្បវេណីដែល

---

[40] *សូមមើលផងដែរ,* ឧបសម្ព័ន្ធ ៣.៨៖ គម្រោងអណ្ដើក, របាយការណ៍នៃការអនុវត្ត។

[41] ឧបសម្ព័ន្ធ ៣.៤៖ គម្រោងអណ្ដើក។ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, កិច្ចព្រមព្រៀងនៃការផ្ដល់ជំនួយគាំទ្ររបស់អង្គការ UNOPS។ ឧបសម្ព័ន្ធ ៣.៥៖ គម្រោងអណ្ដើក។ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, ឯកសារឆ្នាំ ២០១៥-២០១៧ របស់ IFA។

[42] *សូមមើល ឧទាហរណ៍* ប្រតិចារឹកនៃការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ើ ពៅ, ថ្ងៃទី ២៩ ខែកុម្ភៈ ឆ្នាំ ២០១៦, **E1/393.1,** [កែតម្រូវ១] ,ទំព័រ៧, បន្ទាត់ទី១៥ ដល់ទំព័រ១៨ (“ឱ្យលះបង់សាសនា គឺមិនឱ្យគោរពសាសនា ហើយមិនឱ្យប្រើភាសាចាមជាភាសាដើមទេ បើអ្នកណាហើយនិយាយ អង្គការនឹងយកទៅប្រហារជីវិត។ នេះហើយធ្វើឱ្យខ្ញុំមានការភ័យភិត មានការតក់ស្លុត គ្មានអ្វីទីពឹង”)។ ប្រតិចារឹកនៃការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់ របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ើ ពៅ, ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦, **E1/393.1,** [កែតម្រូវ១] ,ទំព័រ៨, បន្ទាត់ទី២២ ដល់ទំព័រ១៨ បន្ទាត់ទី១

*បណ្ដឹងទាមទារចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់សំណង នៅក្នុងសំណុំរឿង ០០២/០២ ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់*

ទទួលរងគ្រោះដោយសារបទបញ្ជាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ [44] ។ សហមេធាវីនាំមុខយល់ឃើញថា គម្រោងខាងក្រោមនេះមានផលប៉ះពាល់

---

(“ខ្មែរក្រហមឲ្យហូបសាច់ជ្រូក។ អ្វីៗដែលខ្មែរធ្វើទៅបាន គឺឲ្យជនជាតិចាមធ្វើតាមទាំងអស់។ នេះហើយហៅថាការលំបាកវេទនា អាហារក៏គ្មាន សាសនាក៏គ្មាន អ្វីៗក៏គ្មាន”។) ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន ស្លេះ, ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦, **E1/393.1**, **[កែតម្រូវ១]** ,ទំព័រ៦៥, បន្ទាត់ទី៣ ដល់ទំព័រ៩ (“នៅពេលដែលចប់របបខ្មែរក្រហម ចាស់ៗស្លាប់អស់ហើយ ក្មេងៗជំនាន់ក្រោយទៅរៀនបន្តនៅស្រុកក្រៅ ដូចប្រទេសអារ៉ាប់ សាអូឌីត នៅម៉ាឡេ អ្នកចេះដឹងបន្តវេនពីចាស់ៗជំនាន់នោះ។ មានច្រើន មានតួន មានអីបង្រៀនខាងសាសនាអ៊ីស្លាម មានបង្រៀនភាសាខ្មែរ ភាសាអង់គ្លេស ដូចខ្មែរជាតិដែរ”។)

[43] *សូមមើល* សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២/០២, **E457/6/2**, ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧, ផ្នែកទី២, ជំពូក ៧ (ឃ) និងឧទាហរណ៍ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំងថែង, ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥, **E1/393.1**, **[កែតម្រូវ១]**, ទំព័រ២៧, បន្ទាត់ទី២ ដល់ទំព័រ៣ (“ផ្ទះយើងត្រូវបានដុតបំផ្លាញជាមួយនឹងសៀវភៅគ្រួសាររបស់យើង។ របស់របរទាំងអស់នៅនឹងផ្ទះ ដុតចោលអស់ហើយ នៅអីទៀត”)។ ឧទាហរណ៍ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំងថែង, ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥, **E1/363.1**, **[កែតម្រូវ១]**, ទំព័រ៧២, បន្ទាត់ទី២ ដល់ទំព័រ ២៣, បន្ទាត់ទី៣ (“ខ្ញុំឥឡូវចងចាំមិនបាន។ អារឿងភ្លេចភ្លាំងហ្នឹង ត្រឹមកាលណាវិបាកខ្លួន ខ្ញុំភ្លេចហើយ។ កាលណាដូចជាខ្ញុំឈឺ ខ្ញុំអត់ចំណាំបាននៅប្រទេសខ្មែរអីចឹងបាន។ បើថាកាលណាខ្ញុំឈឺចាប់ ខ្ញុំដាក់នៅក្នុងចិត្តហើយ ខ្ញុំត្រូវនិយាយចេញទាំងអស់ប៉ុណ្ណឹង”។)

[44] *សូមមើល ឧទាហរណ៍* ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប, ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦, **E1/466.1**, ទំព័រ៧៨, បន្ទាត់ទី៤ ដល់ទំព័រ១៦ (“គឺថាខុសគ្នាដាច់។ ដូចសម័យខ្មែរក្រហមរៀបការតែហៅដាក់ៗ ម្តងបួនដប់គូ ម្តងបួនប្រាំគូ ម្តង១០០គូ ក៏មានដែរ។ រួចចុះចំណែកសម័យឥឡូវនេះ គេរៀបការម្តងតែមួយគូៗ ហើយមានភ្លេងមានភ្លាត់ មានម៉ែមានឪ មានយាយតា ជីដូនជីតា បងប្អូន ហើយមានហែជំនូន ហែផ្កាស្លា បាចផ្កាស្លា បើប្រៀបធៀបខុសគ្នាមិនដឹងប្រដូចទៅនឹងស្អីទេនេះ បើប្រៀបដូចមេឃនិងដីទៅ ក៏វាមិនតិចជាផង។ បានថាខ្ញុំតូចចិត្តដែរហ្នឹង ដល់ឃើញសព្វថ្ងៃ មកហើយសម័យឥឡូវនិងសម័យពីដើម តូចចិត្តនឹងវាសនាខ្លួនឯង។”) ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន, ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៦, **E1/477.1**, ទំព័រ២៤, បន្ទាត់ទី១៥ ដល់ទំព័រ១៩ (“ដល់រៀបៗរួចហើយនេះ កាលណាដែលយើងធ្វើការងារ នៅគេបង្ខំចិត្តរួមដំណេក ការរំលោភ ការមើលងាយ មើលថោក ឲ្យយើងឈឺចាប់។ ឈឺចាប់យ៉ាងខ្លាំងនៅក្នុងជីវិតរបស់ខ្ញុំនេះ ថាគ្មានប្រៀបធៀបបានទេ។ ទោះបីជាខ្ញុំស្លាប់ ក៏ខ្ញុំនៅការចងចាំចំពោះរបបដែលបានធ្វើអំពើឧក្រិដ្ឋកម្មចំពោះរូបខ្ញុំ”)។ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល, ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៦, **E1/464.1**, ទំព័រ៦១, បន្ទាត់ទី១៤ ដល់១៧ និងបន្ទាត់ទី១៩ ដល់២១ (“សោកស្តាយត្រង់ថា គូដណ្តឹងរបស់ខ្ញុំហ្នឹងត្រូវបានគ្នាជាប្តីប្រពន្ធទៅអនាគត ហើយមិនបានក្លាដូចជាផ្លែឈើកំពុងតែពេញហើយ បេះដាច់មិតមកដូចផ្លែស្វាយស្រក់ជ័រ អាខ្ញុំពេលហ្នឹងនៅប្រធានកងហ្នឹងផ្តាច់មនោសញ្ចេតនាខ្ញុំ ហើយខ្ញុំគ្មានសិទ្ធិតវ៉ាអី

ទៅលើវិធានការសំណងផ្លូវចិត្ត ការមិនកើតឡើងជាថ្មី និងឆ្លើយតបនឹងព្យសនកម្មដែលក្រុមដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះទាំងនេះបានទទួលរង និងលើកកម្ពស់ការយល់ដឹងអំពីឧក្រិដ្ឋកម្មដែលប៉ះពាល់ជាសំខាន់ទៅលើប្រជាជនក្នុងក្រុមទាំងនេះ។ ដូច្នេះ សហមេធាវីនាំមុខស្នើសុំឱ្យទទួលស្គាល់គម្រោងទាំងនេះជាការអនុវត្តសំណងរបស់តុលាការក្នុងសំណុំរឿង០០២/០២។

## (៤) គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម

27. សមាគមវប្បធម៌កម្ពុជាសហព័ន្ធអាល្លឺម៉ង់ សហការជាមួយសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានបង្កើត និងអនុវត្ត "គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម"[45] សម្រាប់ជាប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណីចាម គ្រួសាររបស់ពួកគាត់ និងមនុស្សជំនាន់ក្រោយ តាមរយៈការអប់រំសាធារណជនអំពីបទពិសោធន៍របស់សហគមន៍ចាមក្នុងសម័យខ្មែរក្រហម [46]។ តាមរយៈសកម្មភាពគម្រោង អ្នកថតរូបវ័យក្មេង ផលិតករភាពយន្ត និងអ្នកស្រាវជ្រាវមកពីសហគមន៍ជនជាតិចាម បានបង្កើតរឿងផ្ទាល់ខ្លួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជនជាតិចាមទៅជាខ្សែភាពយន្តចំនួនពីរ[47]។ គម្រោងនេះបានចាប់ផ្ដើមអនុវត្តនៅដើមឆ្នាំ ២០១៦។ កាលពីថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៦ សមាគមវប្បធម៌កម្ពុជាសហព័ន្ធអាល្លឺម៉ង់ បានចាប់ផ្ដើមដាក់បញ្ចាំងខ្សែភាពយន្តឯកសារ ដែលមានចំណងជើងថា "ការបះបោររបស់ប្រជាជនចាមនៅស្វាយឃ្លាំង" និងការតាំងពិពណ៌នាសម្ភារផ្សព្វផ្សាយ "ប្រជាជនចាម និងខ្មែរក្រហម"។ ក្នុងឆ្នាំ

---

មានតែចុកទ្រូង ចុកថ្លើម ពិបាកក្នុងចិត្ត។ សព្វថ្ងៃឱ្យតែនឹកឃើញរឿងហ្នឹង ខ្ញុំដូចថាវាហួសចិត្តតែម្ដង។ ខ្ញុំនឹកថាកើតមកវាជាតិនេះ ហើយចំសម័យអីវេទនាខ្លាំងម្ល៉េះ"។)

[45] ឧបសម្ព័ន្ធ ៤៖ គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម។ *សូមមើលផងដែរ,* របាយការណ៍បណ្ដោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីសំណងនៅក្នុងសំណុំរឿង០០២/០២ និងសំណើពាក់ព័ន្ធ, **E352**, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ២១ និងឧបសម្ព័ន្ធសម្ងាត់ទី១ (គម្រោងទី១៣), **E352.2** ។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង ០០២/០២, **E352/2/1**, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ២៧-២៩ និងឧបសម្ព័ន្ធ ៣៖ គម្រោងត្រូវបានចាត់ជាអាទិភាព (គម្រោងទី៣), **E352/2/1.2.3**។

[46] ឧបសម្ព័ន្ធ ៤.២៖ គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម។ ទិដ្ឋភាពរួមស្ដីពីសំណង។

[47] ឧបសម្ព័ន្ធ ៤.២៖ គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម។ ទិដ្ឋភាពរួមស្ដីពីសំណង។ ឧបសម្ព័ន្ធ ៤.៧៖ គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម។ ទិដ្ឋភាពរួមស្ដីពីសំណង។ របាយការណ៍ស្ដីពីការអនុវត្ត។

២០១៧ កញ្ចប់សម្ភារឯកសារផ្សព្វផ្សាយនេះនឹងត្រូវបានផលិតជាខ្សែភាពយន្តជាភាសាចាម ខ្មែរ និងអង់គ្លេស។ គេហទំព័រ និង Blog នឹងដាក់អម និងផ្តល់ជូនបន្ថែមទៅនឹងគម្រោងនេះ ដើម្បីឱ្យមនុស្សជំនាន់ក្រោយក្នុងប្រទេសកម្ពុជាអាចទស្សនាកាន់តែច្រើន[48] ។

28. គម្រោងនេះផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងឆ្លើយតបទៅនឹងព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីជនជាតិចាម បានទទួលរង ជាពិសេស តាមរយៈការអប់រំដល់សហគមន៍អំពីការប្រព្រឹត្តិលើជនជាតិចាមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងកត់ត្រាជាឯកសារអំពីបទពិសោធន៍របស់ពួកគាត់សម្រាប់មនុស្សជំនាន់ក្រោយ។ ខ្សែភាពយន្តឯកសារក៏មានបង្ហាញវត្តមានដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់ និងមានការចូលរួមពីកូនៗរបស់ពួកគេនៅក្នុងការរៀបចំបង្កើតគម្រោងនេះ[49]។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៧ នាក់ និងយុវជនមកពីសហគមន៍ជនជាតិចាម ត្រូវបានអញ្ជើញឱ្យចូលរួមពិធីចាប់ផ្តើមផ្សព្វផ្សាយគម្រោងនេះ។

29. គម្រោងនេះបានទទួលការឧបត្ថម្ភថវិកាទាំងស្រុងពីស្ថានទូតស្វីសប្រចាំក្រុងបាងកក និងមូលនិធិ Heinrich-Böll [50]។

### (៥) ផ្កាស្លាក្រោមអង្គការ

30. វិទ្យាស្ថានសិល្បៈខ្មែរ (The Khmer Arts Academy) សហការជាមួយអង្គការក្តីករុណាមជ្ឈមណ្ឌលបុប្ផាណា និងអង្គការចិត្តសង្គមអន្តរវប្បធម៌ បានបង្កើត និងកំពុងអនុវត្តគម្រោង "ផ្កាស្លាក្រោមអង្គការ" ដែលជាគម្រោងសំណងរបស់តុលាការដែលបានស្នើឡើង ដោយមានកិច្ច

---

[48] ឧបសម្ព័ន្ធ ៤.២៖ គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម។ ទិដ្ឋភាពរួមស្តីពីសំណង។ ឧបសម្ព័ន្ធ ៤.៧៖ គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម។ ទិដ្ឋភាពរួមស្តីពីសំណង។ របាយការណ៍ស្តីពីការអនុវត្ត។

[49] ឧបសម្ព័ន្ធ ៤.២៖ គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម។ របាយការណ៍ស្តីពីការអនុវត្ត។

[50] ឧបសម្ព័ន្ធ ៤.២៖ គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម។ ការផ្ទៀងផ្ទាត់អំពីការធានាបានផ្នែកមូលនិធិ, កិច្ចព្រមព្រៀងរវាងស្ថានទូតស្វីសប្រចាំក្រុងបាងកក និងសមាគមវប្បធម៌កម្ពុជាអាល្លឺម៉ង់។ ឧបសម្ព័ន្ធ ៤.២៖ គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម។ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, កិច្ចព្រមព្រៀងរវាងសមាគមវប្បធម៌កម្ពុជាអាល្លឺម៉ង់ និងមូលនិធិ Heinrich-Böll។

សហការពីសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ [51]។ គម្រោងនេះបានបង្កើតឡើងនូវរបាំបុរាណ និងការតាំងពិពណ៌នា ដោយលើកឡើងពីការបង្ខំឲ្យរៀបការក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ គម្រោងនេះរួមមានការសម្តែងជាសាធារណៈ ការសន្ទនាតាមសហគមន៍ និងអន្តរជំនាន់ ដើម្បីជំរុញការពិភាក្សាជាសាធារណៈ និងការយល់ដឹងថាតើអាពាហ៍ពិពាហ៍ ត្រូវបានកំណត់យ៉ាងដូចម្តេចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[52]។ គម្រោងនេះបានចាប់ផ្តើមអនុវត្តនៅក្នុងខែ ឧសភា ឆ្នាំ ២០១៦ ហើយសកម្មភាពគម្រោងនេះរំពឹងថានឹងត្រូវបញ្ចប់នៅខែ មីនា ឆ្នាំ ២០១៨[53]។ កាលពីថ្ងៃទី ២០ ២១ និង ២២ ខែ មករា ឆ្នាំ ២០១៧ ដៃគូអនុវត្តបានចាប់ផ្តើមបង្កើតរបាំបូរាណ និងតាំងពិពណ៌ពាក់ព័ន្ធនឹងគម្រោង "ផ្កាស្លាក្រោមអង្គការ" នៅភ្នំពេញ [54]។ ការសម្តែង និងការតាំងពិពណ៌មួយទៀត ត្រូវបានធ្វើឡើងនៅបាត់ដំបង កាលពីថ្ងៃទី ៦ ខែ ឧសភា និងបន្ទាប់ទៀត ត្រូវបានគ្រោងធ្វើនៅខេត្តកំពត ក្នុងខែ កក្កដា ឆ្នាំ ២០១៧។

31. គម្រោងនេះផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងឆ្លើយតបទៅនឹងព្យសនកម្មនៃការបទបញ្ជាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ គម្រោងនេះក៏បានជំរុញឲ្យមានការពិភាក្សា ដើម្បីទទួលបានការយល់ដឹងកាន់តែប្រសើរឡើងអំពីបទពិសោធន៍ទាំងនោះ។ តាមរយៈការពិគ្រោះយោបល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៥០នាក់ កាលពីថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៦ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ និងថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ គម្រោងនេះបានដាក់បញ្ចូលទស្សនៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការរៀបចំបង្កើតការសម្តែងរបាំបូរាណ និងការតាំងពិពណ៌ដែលពាក់ព័ន្ធ។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រហែល ១៤០ នាក់ បានចូលរួមការចាប់ផ្តើមនៃការសម្តែង និងការ

---

[51] ឧបសម្ព័ន្ធ ៥៖ ផ្កាស្លាក្រោមអង្គការ។ *សូមមើលផងដែរ,* របាយការណ៍បណ្តោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណងនៅក្នុងសំណុំរឿង០០២/០២ និងសំណើពាក់ព័ន្ធ, **E352**, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ២១ និងឧបសម្ព័ន្ធសម្ងាត់ទី១ (គម្រោងទី១៧), **E352.2** ។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង០០២/០២, **E352/2/1**, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ៣០-៣៣ និងឧបសម្ព័ន្ធ ៣៖ គម្រោងត្រូវបានចាត់ជាអាទិភាព (គម្រោងទី៣), **E352/2/1.2.3**។

[52] ឧបសម្ព័ន្ធ ៥.២៖ ផ្កាស្លាក្រោមអង្គការ, សំណើគម្រោងសំណង។

[53] ឧបសម្ព័ន្ធ ៥.២៖ ផ្កាស្លាក្រោមអង្គការ, សំណើគម្រោងសំណង។

[54] ឧបសម្ព័ន្ធ ៥.៨៖ ផ្កាស្លាក្រោមអង្គការ, ប័ណ្ណផ្សព្វផ្សាយសម្រាប់គម្រោងផ្កាស្លា។

តាំងពិពណ៌ក្នុងខែ មករា ឆ្នាំ ២០១៧ និងបានចូលរួមនៅក្នុងសកម្មភាពគម្រោង មុន និងក្រោយការសម្តែង។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៥០នាក់ ត្រូវបានរំពឹងចូលរួមការសម្តែង និងការតាំងពិពណ៌នៅខេត្តកំពត។

32. គម្រោងនេះបានទទួលការឧបត្ថម្ភថវិកាទាំងស្រុងពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រទេសស្វីស ក្រសួងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហព័ន្ធអាល្លឺម៉ង់ តាមរយៈ Deutschen Gesellschaft für Internationale Zusammenarbeit (GIZ) GbmH និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)[55]។

### (៦) សំឡេងពីជនជាតិភាគតិច៖ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តិមកលើជនជាតិភាគតិចវៀតណាម និងចាម ដែលបានរស់នៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងរបបខ្មែរក្រហម

33. អង្គការក្តីករុណា សហការជាមួយសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានបង្កើត និងកំពុងអនុវត្តគម្រោង *"សំឡេងពីជនជាតិភាគតិច៖ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តិមកលើជនជាតិភាគតិចវៀតណាម និងចាម ដែលបានរស់នៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងរបបខ្មែរក្រហម"* ដែលជាគម្រោងសំណងរបស់តុលាការដែលបានស្នើឡើង[56]។ គម្រោងនេះត្រូវបានបង្កើតឡើង ដើម្បីផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីជនជាតិភាគតិចចាម និងវៀតណាម តាមរយៈការកត់ត្រាឯកសារ និងដាក់បង្ហាញបទពិសោធន៍របស់

---

[55] ឧបសម្ព័ន្ធ ៥.៨៖ ផ្កាស្លាក្រោមអង្គការ។ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, កិច្ចសន្យារវាង SDC និងវិទ្យាស្ថានសិល្បៈខ្មែរ។ ឧបសម្ព័ន្ធ ៥.៦៖ ផ្កាស្លាក្រោមអង្គការ។ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, កិច្ចសន្យារវាង GIZ និង អ.វ.ត.ក។ ឧបសម្ព័ន្ធ ៥.៧៖ ផ្កាស្លាក្រោមអង្គការ។ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, ការកែសម្រួលជំនួយ, USAID។

[56] ឧបសម្ព័ន្ធ ៦៖ សំឡេងពីជនជាតិភាគតិច៖ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តិមកលើជនជាតិភាគតិចវៀតណាម និងចាម ដែលបានរស់នៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងរបបខ្មែរក្រហម។ *សូមមើលផងដែរ,* របាយការណ៍បណ្តោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណងនៅក្នុងសំណុំរឿង០០២/០២ និងសំណើពាក់ព័ន្ធ, **E352**, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ២១ និងឧបសម្ព័ន្ធសម្ងាត់ទី១ (គម្រោងទី១៥), **E352.2** ។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង ០០២/០២, **E352/2/1**, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ៣៤-៣៦ និងឧបសម្ព័ន្ធ ៣៖ គម្រោងត្រូវបានចាត់ជាអាទិភាព (គម្រោងទី៣), **E352/2/1.2.3**។

ពួកគេ និងផ្ដល់ឱកាសនៃការសន្ទនាអន្តរជំនាន់អំពីការប្រព្រឹត្តិទៅលើពួកគេក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ គម្រោងនេះលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីមូលហេតុ និងផលវិបាកនៃអំពើហិង្សា និងការរើសអើងប្រឆាំងនឹងដើមបណ្ដឹងរដ្ឋប្បវេណីជាជនជាតិភាគតិចវៀតណាម តាមរយៈការតាំងពិពណ៌ចល័ត ការសន្ទានាអន្តរជំនាន់ ការបោះពុម្ពផ្សាយរឿងប្រលោមលោកអមទៅដោយរូបភាព និងវេទិកាមហោស្រព[57]។

34. គម្រោងនេះផ្ដល់ប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ជាពិសេស អ្នកដែលជាជនជាតិចាម ឬជនជាតិភាគតិចវៀតណាម និងឆ្លើយតបទៅនឹងព្យសនកម្មដែលជាផលវិបាកនៃឧក្រិដ្ឋកម្មនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ ដោយលើកកម្ពស់ការយល់ដឹងជាសាធារណៈ ឆ្លើយតបទៅនឹងទស្សនៈយល់ឃើញទូទៅ លើកកម្ពស់ការប្រឆាំងនឹងការរើសអើង ផ្ដល់ឱកាសសម្រាប់ការសន្ទានាជាសាធារណៈ និងកត់ត្រាបទពិសោធន៍របស់ក្រុមជនជាតិភាគតិចទាំងនោះ។ កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ អង្គការក្ដីករុណាបានចាប់ផ្ដើមតាំងពិពណ៌ចល័ត ដែលជាផ្នែកមួយនៃគម្រោង នៅភ្នំពេញ ដោយមានដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១២ នាក់ ចូលរួមក្នុងពិធីនេះ។ កាលពីថ្ងៃទី ៨ និងទី៩ ខែ ធ្នូ ឆ្នាំ ២០១៦ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១៤ នាក់ បានចូលរួមក្នុងការតាំងពិពណ៌ចល័ត ដែលបានធ្វើឡើងនៅកំពង់ឆ្នាំង ហើយកាលពីថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៦ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៥ នាក់ បានចូលរួមការសម្ពោធផ្សព្វផ្សាយសៀវភៅប្រលោមលោកអមដោយរូបភាព និងកិច្ចពិគ្រោះយោបល់ដែលពាក់ព័ន្ធនៅភ្នំពេញ។ កាលពីថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១៧ អង្គការក្ដីករុណា ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងវេទិកាដើមបណ្ដឹងរដ្ឋប្បវេណីមួយនៅកំពង់ចាម ដែលមានវត្តមានដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១៣៥ នាក់។ ពីថ្ងៃទី ៦ ដល់ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១៧ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៤ នាក់ បានចូលរួមក្នុងពិធីតាំងពិពណ៌ចល័តដែលបានធ្វើឡើងនៅព្រៃវែង។

35. គម្រោងនេះបានទទួលការឧបត្ថម្ភថវិកាទាំងស្រុងពីក្រសួងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ តាមរយៈសេវាសន្តិភាពសម្រាប់ពលរដ្ឋ (ZFD) នៃ Deutschen

---

[57] ឧបសម្ព័ន្ធ ៦.២៖ សំឡេងពីជនជាតិភាគតិច៖ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តិមកលើជនជាតិភាគតិចវៀតណាម និងចាម ដែលបានរស់នៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងរបបខ្មែរក្រហម។ ទិដ្ឋភាពរួមអំពីគម្រោងសំណង។ *បណ្ដឹងទាមទារចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់សំណង នៅក្នុងសំណុំរឿង ០០២/០២ ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់*

Gesellschaft für Internationale Zusammenarbeit (GIZ) GbmH និងស្ថានទូតស្វីសប្រចាំក្រុងបាងកក[58]។

## គ. ការពេញចិត្ត

36. ការពេញចិត្តចំពោះសំណង រួមមាន *ក្នុងចំណោមនោះ* ការបញ្ជាក់ការពិត ការបង្ហាញការពិតពេញលេញ និងជាសាធារណៈ ការរំលឹក និងការគោរពដល់ជនរងគ្រោះ និងការដាក់បញ្ចូលការពិពណ៌នាដ៏ត្រឹមត្រូវអំពីឧក្រិដ្ឋកម្មទាំងឡាយទៅក្នុងសម្ភារអប់រំនៅគ្រប់កម្រិត[59]។ ដើមបណ្តឹងរដ្ឋប្បវេណីតែងបានស្នើសុំឱ្យកសាងទីបូជនីយដ្ឋាន រៀបចំពិធីនានា និងស្នើសុំឱកាស ដើម្បីចែករំលែកបទពិសោធន៍របស់ពួកគាត់ តាមរយៈការប្រាប់អំពីការពិត។ ដូចបានពិពណ៌នានៅក្នុងផ្នែកស្តីពីព្យសនកម្ម បន្ទាប់ពីជំពូកនីមួយៗក្នុងផ្នែកទី៥ [60] និងសំណួរទៅកាន់ជនជាប់ចោទ [61] ដើម

[58] ឧបសម្ព័ន្ធ ៦.៥៖ សំឡេងពីជនជាតិភាគតិច៖ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តិមកលើជនជាតិភាគតិចវៀតណាម និងចាម ដែលបានរស់នៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងរបបខ្មែរក្រហម។ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ។ កិច្ចព្រមព្រៀងរវាងស្ថានទូតស្វីសប្រចាំក្រុងបាងកក និងអង្គការក្តីករុណា។ ឧបសម្ព័ន្ធ ៦.៥៖ សំឡេងពីជនជាតិភាគតិច៖ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តិមកលើជនជាតិភាគតិចវៀតណាម និងចាម ដែលបានរស់នៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងរបបខ្មែរក្រហម។ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ។ កិច្ចព្រមព្រៀងរវាង GIZ និងអង្គការក្តីករុណា។

[59] គោលការណ៍ និងគោលការណ៍ណែនាំជាមូលដ្ឋានស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភដ៏កម្រោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ, សេចក្តីសម្រេចលេខ ៦០/១៧៤,មហាសន្និបាតអង្គការសហប្រជាជាតិ, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥, មាត្រា២២។

[60] *សូមមើល ឧទាហរណ៍* ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី បេង បឿន, ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥, **E1/287.1, [**កែតម្រូវ១**]** ,ទំព័រ៦៦, បន្ទាត់ទី៩ ដល់ទំព័រ១២ (“ហេតុអ្វីបានជាមិនឱ្យទៅមើលអ្នកដែលឈឺ? ទាក់ទងនឹងករណីឪពុកក្មេករបស់ខ្ញុំ ហេតុអ្វីបានជាមិនឱ្យទៅមើលអ្នកដែលជិតស្លាប់?”)។ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សុគ្គានី, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥, **E1/306.1, [**កែតម្រូវ១**]** ,ទំព័រ១៩, បន្ទាត់ទី២០ ដល់ទំព័រ២១ (“ចង់ធ្វើបុណ្យក៏មិនបាន ចង់ឧទ្ទិសអីក៏មិនបាន ចង់ទៅមើលប្អូនជាលើកចុងក្រោយក៏មិនបាន”)។ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា, ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥, **E1/308.1, [**កែតម្រូវ១**]** ,ទំព័រ៩០, បន្ទាត់ទី២២ ដល់ទំព័រ៩១ បន្ទាត់ទី២ (“ខ្ញុំជំរុញឱ្យពួកគេនិយាយការពិត ហើយកុំកុហក ឬផ្តល់លេសកហុស **[...]** សូមឱ្យមនុស្សជំនាន់ក្រោយនៅកម្ពុជា យល់ដឹងពីការពិត យល់ដឹងពីប្រវត្តិសាស្ត្រដែលបានកើតឡើង**...**”)។ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន, ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦, E1/457.1, **[**កែតម្រូវ១**]** ,ទំព័រ១៤, បន្ទាត់ទី១៦ ដល់ទំព័រ៥ បន្ទាត់ទី៣ (“ខ្ញុំបានប្រាប់ដល់ព្រលឹងរបស់សព

*បណ្តឹងទាមទារចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណង នៅក្នុងសំណុំរឿង ០០២/០២ ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់*

បណ្ដឹងរដ្ឋប្បវេណីបានលើកឡើងវិញនូវបំណងប្រាថ្នាទាំងនេះក្នុងអំឡុងសក្ខីកម្មរបស់ពួកគាត់នៅតុលាការ។

37. ដើមបណ្ដឹងរដ្ឋប្បវេណីយល់ឃើញថា គម្រោងទាំងពីរខាងក្រោមនេះមានផលប៉ះពាល់ដល់វិធានការសំណងនៃការពេញចិត្ត និងផ្ដល់ប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណីចំពោះព្យសនកម្មដែលបានទទួលរងដែលជាផលវិបាកនៃឧក្រិដ្ឋកម្មដែលបានចោទក្នុងសំណុំរឿង០០២/០២ និងស្នើឲ្យអង្គជំនុំជម្រះអនុម័តលើគម្រោងទាំងនេះថាជាការអនុវត្តសំណងតុលាការ។

### **(៧) រឿងរ៉ាវដែលមិនធ្លាប់បានគេដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានចូលរួមក្នុងសំណុំរឿង ០០២/ ០២ នៅ អ.វ.ត.ក**

38. អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ដោយមានកិច្ចសហការជាមួយសហមេធាវីនាំមុខ និងអង្គភាពជនរងគ្រោះ បានបង្កើត និងកំពុងអនុវត្តគម្រោង "រឿងរ៉ាវដែលមិនបាន

---

អ្នកស្លាប់នៅវណ្ដៅនោះថា នៅពេលដែល ប្រសិនបើខ្ញុំអាចរត់គេចពីទៅនោះបាន ខ្ញុំនឹងស្វែងរកយុត្តិធម៌ឲ្យពួកគេ")។ ប្រតិចារឹកនៃការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី [redacted], ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៧, E1/417.1, [កែតម្រូវ១] ,ទំព័រ១៤, បន្ទាត់ទី១៦ ដល់ទំព័រ៥ បន្ទាត់ទី៣ ("ពេលនោះយើងមានការឈឺចាប់ខ្លាំងណាស់បាទ ឈឺចាប់ខ្លាំងមែនទែន។ យើងនឹកថាខ្ញុំទៅថ្ងៃក្រោយ ខ្ញុំនឹងជម្រាបប្រាប់ពិភពលោកឲ្យគេបានដឹងការពិត។)

[61] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលនៅក្នុងសំណុំរឿង០០២/០២, ឧបសម្ព័ន្ធ ង៖ សំណួរទៅកាន់ជនជាប់ចោទ, **E457/6/2.2.6**, ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧។ *សូមមើល ឧទាហរណ៍* ប្រតិចារឹកនៃការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ូ ដាវ, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦, **E1/499.1,** [កែតម្រូវ១] ,ទំព័រ៦៦, បន្ទាត់ទី៩ ដល់ទំព័រ១២ ("នៅពេលមានតុលាការជាតិ អន្តរជាតិ ខ្ញុំក៏ដាក់ពាក្យបណ្ដឹង ជាដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីរកយុត្តិធម៌ជូនដល់លោកឪពុកម្ដាយបងប្អូនសាច់ញាតិ ព្រមទាំងបងប្អូន២លាននាក់ជាងនោះ ដែលត្រូវស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ")។ ប្រតិចារឹកនៃការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់, ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦, **E1/483.1,** [កែតម្រូវ១] ,ទំព័រ៦៩, បន្ទាត់ទី១៧ ដល់ទំព័រ២០ ("ខ្ញុំសូមទាមទារសំណងដូចជា វត្តអារាម សាលារៀន ឲ្យកូនក្មេងសាក្រោយចេះដឹង កុំឲ្យល្ងិតល្ងង់ដូចខ្ញុំ")។ ប្រតិចារឹកនៃការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥, **E1/2253.1,** [កែតម្រូវ១] ,ទំព័រ៨៦, បន្ទាត់ទី៦ ដល់ទំព័រ៧ ("ខ្ញុំសូមឲ្យតុលាការជួយបំភ្លឺរឿងនេះនិងរកយុត្តិធម៌")។ ប្រតិចារឹកនៃការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណែម, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦, **E1/488.1,** [កែតម្រូវ១] ,ទំព័រ១១៦, បន្ទាត់ទី១៥ ដល់ទំព័រ២៥ ("ខ្ញុំដូចគ្មានយោបល់អីច្រើនដែរ ខ្ញុំគ្រាន់តែសុំឲ្យមេធាវីជួយ ឬមួយលោក ខៀវ សំផន ឬមួយយ៉ាងម៉េច តើបានធ្វើ តើបានអីចឹងមែន ឬមួយយ៉ាងម៉េចបាន")។

គេដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានចូលរួមក្នុងសំណុំរឿង០០២/០២ នៅ អ.វ.ត.ក"[62]។ គម្រោងនេះបានផលិតសៀវភៅអមដោយរូបភាពអំពីការពិពណ៌នារបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានឆ្លងកាត់ឧក្រិដ្ឋកម្មទាំងនោះ និងប្រធានបទដែលបានជំនុំជម្រះក្នុងសំណុំរឿង០០២/០២។ គម្រោងនេះបានចាប់ផ្ដើមប្រមូលដំណើររឿងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងខែ មិថុនា និងបានបញ្ចប់ការផលិតសៀវភៅទាំងនេះក្នុងខែ មិថុនា ឆ្នាំ ២០១៦[63]។

39. គម្រោងនេះផ្ដល់ប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណី តាមរយៈការផ្ដល់ឱកាសឲ្យពួកគាត់រៀបរាប់អំពីដំណើររឿងដែលជាបទពិសោធន៍របស់ខ្លួន សម្រាប់ការផ្សព្វផ្សាយ និងការយល់ដឹងជាសាធារណៈ ព្រមទាំងផ្ដល់ភាពអង់អាច និងការយល់ដឹងអំពីយុត្តិធម៌ ដល់ដើមបណ្ដឹងរដ្ឋប្បវេណី និងបន្ធូរបន្ថយការឈឺចាប់តាមរយៈការទទួលស្គាល់ពីទុក្ខវេទនារបស់ពួកគាត់។ ក្នុងអំឡុងពេលអនុវត្តគម្រោង ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៣០ នាក់ ត្រូវបានសម្ភាសសម្រាប់សៀវភៅអំពីបទពិសោធន៍របស់ពួកគាត់ទាក់ទងនឹងការដាក់បទបញ្ជាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ ការប្រព្រឹត្តិលើពុទ្ធសាសនិកជន មន្ទីរសន្តិសុខ ការដ្ឋាន ឬសហករណ៍។ សៀវភៅចំនួន ៥០០ច្បាប់ត្រូវបានបោះពុម្ពដើម្បីផ្ដល់ជូនដើមបណ្ដឹងរដ្ឋប្បវេណី និងស្ថាប័នអប់រំនានា [64] ។

---

[62] ឧបសម្ព័ន្ធ ៧៖ រឿងរ៉ាវដែលមិនធ្លាប់បានគេដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានចូលរួមក្នុងសំណុំរឿង០០២/០២ នៅ អ.វ.ត.ក។ *សូមមើលផងដែរ,* របាយការណ៍បណ្ដោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីសំណងនៅក្នុងសំណុំរឿង០០២/០២ និងសំណើពាក់ព័ន្ធ, **E352**, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ២០ និងឧបសម្ព័ន្ធសម្ងាត់ទី១ (គម្រោងទី៩), **E352.2** ។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង០០២/០២, **E352/2/1**, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ៣៨-៤០ និងឧបសម្ព័ន្ធ ៣៖ គម្រោងត្រូវបានចាត់ជាអាទិភាព (គម្រោងទី៣), **E352/2/1.2.3**។

[63] ឧបសម្ព័ន្ធ ៧.២៖ រឿងរ៉ាវដែលមិនធ្លាប់បានគេដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានចូលរួមក្នុងសំណុំរឿង០០២/០២ នៅ អ.វ.ត.ក។ ទិដ្ឋភាពរួមអំពីគម្រោង។

[64] ឧបសម្ព័ន្ធ ៧.៦៖ រឿងរ៉ាវដែលមិនធ្លាប់បានគេដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានចូលរួមក្នុងសំណុំរឿង០០២/០២ នៅ អ.វ.ត.ក។ ព័ត៌មានស្ដីពីការអនុវត្ត ដែលទទួលបានពីអង្គការ CHRAC។

40. គម្រោងនេះបានទទួលការឧបត្ថម្ភថវិកាទាំងស្រុងពីស្ថានទូតស្វីសប្រចាំក្រុងបាងកក និងមូលនិធិ Heinrich-Böll [65]។

### (៨) ពេលវេលាដែលត្រូវចងចាំ៖ ការប្រកួតប្រជែងរបស់យុវជនក្នុងការតាក់តែងចម្រៀង ស្តីពីការចងចាំនៅកម្ពុជា ឆ្នាំ ២០១៦

41. កម្មវិធីអភិវឌ្ឍធនធានមនុស្ស (“YRDP”) ដោយមានកិច្ចសហការជាមួយសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានរៀបចំបង្កើត និងអនុវត្តពេញលេញចំពោះគម្រោង “ពេលវេលាដែលត្រូវចងចាំ៖ ការប្រកួតប្រជែងរបស់យុវជនក្នុងការតាក់តែងចម្រៀងស្តីពីការចងចាំនៅកម្ពុជា ឆ្នាំ ២០១៦”[66] ដែលជាគម្រោងសំណងដែលបានស្នើឡើង។ គម្រោងនេះទទួលស្គាល់បទពិសោធន៍របស់អ្នកនៅរស់រានមានជីវិត តាមរយៈការលើកកម្ពស់ការសន្ទនាអន្តរជំនាន់រវាងដើមបណ្តឹងរដ្ឋប្បវេណី និងមនុស្សជំនាន់ក្រោយ ដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណីរៀបរាប់អំពីការឈឺចាប់ដែលជាផលវិបាកនៃឧក្រិដ្ឋកម្មដែលជំនុំជម្រះក្នុងសំណុំរឿង០០២/០២[67]។ គម្រោងបានអនុវត្តសកម្មភាព ពីខែ មីនា ដល់ខែ ធ្នូ ឆ្នាំ ២០១៦ និងទទួលបានការគាំទ្រពីក្រសួងវប្បធម៌ និង

---

[65] ឧបសម្ព័ន្ធ ៧.៥៖ រឿងរ៉ាវដែលមិនធ្លាប់បានគេដឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានចូលរួមក្នុងសំណុំរឿង០០២/០២ នៅ អ.វ.ត.ក។ ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, កិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងមូលនិធិ Heinrich-Böll និងអង្គការ CHRAC។

[66] ឧបសម្ព័ន្ធ ៨៖ ពេលវេលាដែលត្រូវចងចាំ៖ ការប្រកួតប្រជែងរបស់យុវជនក្នុងការតាក់តែងចម្រៀង ស្តីពីការចងចាំនៅកម្ពុជា ឆ្នាំ ២០១៦។ *សូមមើលផងដែរ,* របាយការណ៍បណ្តោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណងនៅក្នុងសំណុំរឿង០០២/០២ និងសំណើពាក់ព័ន្ធ, **E352**, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ២០ និងឧបសម្ព័ន្ធសម្ងាត់ទី១ (គម្រោងទី៤), **E352.2** ។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង០០២/០២, **E352/2/1**, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ១៣ និងឧបសម្ព័ន្ធ ២៖ គម្រោងត្រូវបានចាត់ជាអាទិភាព (គម្រោងទី៣), **E352/2/1.2.2**។

[67] ឧបសម្ព័ន្ធ ៨.២៖ ពេលវេលាដែលត្រូវចងចាំ៖ ការប្រកួតប្រជែងរបស់យុវជនក្នុងការតាក់តែងចម្រៀង ស្តីពីការចងចាំនៅកម្ពុជា ឆ្នាំ ២០១៦, ទិដ្ឋភាពរួមស្តីពីសំណង។

វិចិត្រសិល្បៈ[68]។ ការប្រគុំតន្ត្រីលើកចុងក្រោយត្រូវបានធ្វើឡើងនៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១៦ ដោយមានទស្សនិកជនចូលរួមចំនួនជិត ៤០០ នាក់[69]។

42. គម្រោងនេះផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការយល់ដឹង និងការទទួលស្គាល់អំពីការឈឺចាប់របស់ពួកគាត់ ជាពិសេស តាមរយៈការចូលរួមរបស់យុវជនក្នុងគម្រោងតាមរយៈចម្រៀង និងការសម្តែង ព្រមទាំងការសន្ទានាអន្តរជំនាន់។ ក្នុងខែ កុម្ភៈ ឆ្នាំ ២០១៦ YRDP ធ្វើការពិគ្រោះយោបល់ទាក់ទងនឹងការរៀបចំបង្កើតគម្រោងនេះ និងគម្រោងចំនួនពីរទៀតដោយមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤ នាក់ បានចូលរួម។ ពីខែ មីនា ដល់ខែ ឧសភា ឆ្នាំ២០១៦ YRDP បានធ្វើសិក្ខាសាលាពិគ្រោះយោបល់ចំនួន៣លើក ដោយមានមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន១២នាក់ និងយុវជនចំនួន៧៩នាក់ បានចូលរួម ដើម្បីទទួលបាននូវមតិយោបល់លើការរៀបចំបង្កើតគម្រោង។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៤១នាក់ បានចូលរួមការប្រគុំតន្ត្រីចុងក្រោយ និងមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន២នាក់ ធ្វើជាគណៈវិនិច្ឆ័យ[70]។

43. គម្រោងនេះ បានទទួលការឧបត្ថម្ភថវិកាទាំងស្រុងពីក្រសួងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ សហព័ន្ធអាល្លឺម៉ង់ តាមរយៈសេវាសន្តិភាពសម្រាប់ពលរដ្ឋ (ZFD) នៃ Deutschen Gesellschaft für Internationale Zusammenarbeit (GIZ) GbmH [71]។

---

[68] ឧបសម្ព័ន្ធ ៨.២៖ ពេលវេលាដែលត្រូវចងចាំ៖ ការប្រកួតប្រជែងរបស់យុវជនក្នុងការតាក់តែងចម្រៀង ស្តីពីការចងចាំនៅកម្ពុជា ឆ្នាំ ២០១៦, ទិដ្ឋភាពរួមស្តីពីសំណង។ ឧបសម្ព័ន្ធ ៨.៨៖ ពេលវេលាដែលត្រូវចងចាំ៖ ការប្រកួតប្រជែងរបស់យុវជនក្នុងការតាក់តែងចម្រៀង ស្តីពីការចងចាំនៅកម្ពុជា ឆ្នាំ ២០១៦, របាយការណ៍សង្ខេបស្តីពីគម្រោង។ ឧបសម្ព័ន្ធ ៨.៧៖ ពេលវេលាដែលត្រូវចងចាំ៖ ការប្រកួតប្រជែងរបស់យុវជនក្នុងការតាក់តែងចម្រៀង ស្តីពីការចងចាំនៅកម្ពុជា ឆ្នាំ ២០១៦, លិខិតស្តីពីការគាំទ្រពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

[69] ឧបសម្ព័ន្ធ ៨.៨៖ ពេលវេលាដែលត្រូវចងចាំ៖ ការប្រកួតប្រជែងរបស់យុវជនក្នុងការតាក់តែងចម្រៀង ស្តីពីការចងចាំនៅកម្ពុជា ឆ្នាំ ២០១៦, របាយការណ៍សង្ខេបស្តីពីគម្រោង។

[70] ឧបសម្ព័ន្ធ ៨.៨៖ ពេលវេលាដែលត្រូវចងចាំ៖ ការប្រកួតប្រជែងរបស់យុវជនក្នុងការតាក់តែងចម្រៀង ស្តីពីការចងចាំនៅកម្ពុជា ឆ្នាំ ២០១៦, របាយការណ៍សង្ខេបស្តីពីគម្រោង។

[71] ឧបសម្ព័ន្ធ ៨.៦៖ ពេលវេលាដែលត្រូវចងចាំ៖ ការប្រកួតប្រជែងរបស់យុវជនក្នុងការតាក់តែងចម្រៀង ស្តីពីការចងចាំនៅកម្ពុជា ឆ្នាំ ២០១៦, ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ។

### (៩) ផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់

44. អង្គការយុវសន្តិភាព (“YFP”) និងវិទ្យាស្ថានសន្តិភាពកម្ពុជា (“PIC”) បានរៀបចំបង្កើត និងបានអនុវត្តពេញលេញគម្រោង “ផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់” ដោយសហការជាមួយសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ ដែលជាគម្រោងសំណងដែលបានស្នើឡើងសម្រាប់ជាប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០២[72]។ គម្រោងនេះបង្កើតឲ្យមានការតាំងពិពណ៌ផ្ទាំងគំនូរអំពីមន្ទីរសន្តិសុខ ជាមួយនិស្សិតសាកលវិទ្យាល័យ និងមានការពិគ្រោះយោបល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី។ គំនូរទាំងនេះត្រូវបានដាក់បង្ហាញជាសាធារណៈ ហើយកូនសៀវភៅមួយត្រូវបានផលិតឡើង ដើម្បីចងចាំដំណើរការនៃការបង្កើតគម្រោងស្តីពីផ្ទាំងគំនូរនេះ ដើម្បីរួមជាមួយការតាំងបង្ហាញនេះ។ គម្រោងនេះត្រូវបានសម្ពោធជាផ្លូវការនៅថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១៦ ដោយមានការចូលរួមពីសមាជិកសហគមន៍ចំនួន ១១៥ នាក់ យុវជន ព្រះសង្ឃ តំណាងមកពីអាជ្ញាធរមូលដ្ឋាន និងជនរងគ្រោះ/អ្នកនៅរស់រានមានជីវិត[73]។

45. គម្រោងនេះផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការរំឮកអំពីបទពិសោធន៍របស់ពួកគាត់ និងការទទួលស្គាល់អំពីការឈឺចាប់ ដែលជាផលវិបាកនៃឧក្រិដ្ឋកម្មដែលបានចោទនៅមន្ទីរសន្តិសុខក្រាំងតាំចាន់។ គម្រោងនេះក៏ផ្តល់ឱកាសដល់និស្សិតសាកលវិទ្យាល័យ ឲ្យចូលរួមស្តាប់ការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ អំពីបទពិសោធន៍របស់ពួកគាត់ទាក់ទងនឹងមន្ទីរសន្តិសុខក្រាំងតាចាន់។ កាលពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ជាផ្នែកមួយនៃគម្រោង អង្គការយុវសន្តិភាពបានរៀបចំធ្វើសិក្ខាសាលាពិគ្រោះយោបល់មួយស្តីពីផ្ទាំងគំនូរដែលបានគូរដោយយុវនិស្សិតមួយក្រុមដែលមានសាវតារផ្សេងៗគ្នា។ ពីធីនេះត្រូវបានធ្វើឡើងនៅសារៈ

---

[72] ឧបសម្ព័ន្ធទី៩៖ ផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់ ។ *សូមមើលផងដែរ* របាយការណ៍បណ្តោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណងនៅក្នុងសំណុំរឿង០០២/០២ និងសំណើពាក់ព័ន្ធ, **E352**, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ២០ និងឧបសម្ព័ន្ធសម្ងាត់ទី១ (គម្រោងទី៥), **E352.2** ។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង០០២/០២, **E352/2/1**, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ១៣ និងឧបសម្ព័ន្ធ ២៖ គម្រោងស្ថិតក្រោមការពិចារណា (គម្រោងទី៤), **E352/2/1.2.2**។

[73] ឧបសម្ព័ន្ធទី៩៖ ផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់, ទិដ្ឋភាពរួមអំពីគម្រោងសំណង។ ឧបសម្ព័ន្ធទី៩.៦៖ ផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់, របាយការណ៍ចុងក្រោយ។

មន្ទីរក្រាំងតាចាន់ ដែលមានទីតាំងនៅខេត្តតាកែវ ដោយមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ៤នាក់។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤នាក់ បានចូលរួមក្នុងពិធីសម្ពោធគម្រោងនេះ[74]។

46. គម្រោងនេះបានទទួលការឧបត្ថម្ភថវិកាទាំងស្រុងពី International Coalition of Sites of Conscience[75]។

### (១០) ការចូលមើលកំណត់ហេតុតុលាការស្តីពីការកាត់សេចក្តីខ្មែរក្រហម និងសម្ភាររបស់ដើមបណ្តឹង រដ្ឋប្បវេណីនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹង អ.វ.ត.ក (LDC)

47. សហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានចាប់ផ្តើមពិភាក្សាក្នុងឆ្នាំ ២០១៣[76] ជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក ដែលជាលទ្ធផល ទីស្តីការគណៈរដ្ឋមន្ត្រីនៃព្រះរាជណាចក្រកម្ពុជា បានស្នើគម្រោងស្តីពី “ការចូលមើលកំណត់ហេតុតុលាការស្តីពីការកាត់សេចក្តីខ្មែរក្រហម និងសម្ភាររបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធ អ.វ.ត.ក (LDC)” ដែលជាគម្រោងសំណងតុលាការមួយដែលបានស្នើឡើងក្នុងសំណុំរឿង០០២[77]។ មជ្ឈមណ្ឌលនេះបានបង្កើតបណ្តុំឯកសារសាធារណៈដែលអាច

---

[74] ឧបសម្ព័ន្ធទី៩.៦៖ ផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់, របាយការណ៍ចុងក្រោយ។

[75] ឧបសម្ព័ន្ធទី៩.៤៖ ផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់, លិខិតផ្ទៀងផ្ទាត់ការអនុវត្តទាំងស្រុងជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ។ ឧបសម្ព័ន្ធទី៩.៥៖ ផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់, ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, លិខិតពី International Coalition of Sites of Conscience ស្តីពីការអនុម័តថវិកា។

[76] សំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់ ឧបសម្ព័ន្ធ ១៖ ឯកសារពាក់ព័ន្ធនឹងគម្រោងទីមួយ៖ ទិវាជាតិនៃការចងចាំ ឯកសារ **E218/7/6.1.1**, ERN (KH) 00950869។

[77] ឧបសម្ព័ន្ធទី ១០៖ការចូលមើលកំណត់ហេតុតុលាការស្តីពីការកាត់សេចក្តីខ្មែរក្រហម និងសម្ភារៈរបស់ដើមបណ្តឹង រដ្ឋប្បវេណីនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធ អ.វ.ត.ក (LDC)។ *សូមមើលផងដែរ* របាយការណ៍បណ្តោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណងនៅក្នុងសំណុំរឿង០០២/០២ និងសំណើពាក់ព័ន្ធ, **E352**, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ១១ ។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង០០២/០២, **E352/2/1**, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ៤១ ដល់៤៣ ឧបសម្ព័ន្ធទី ១៖ អនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអង្គភាពគាំពារជនរងគ្រោះ ជូនចំពោះឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទាក់ទងនឹងសំណើរួមរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអង្គភាពគាំពារជនរងគ្រោះ សុំឲ្យមានការចូលរួមពីសំណាក់រាជរដ្ឋាភិបាល *បណ្តឹងទាមទារចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណង នៅក្នុងសំណុំរឿង ០០២/០២ ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់*

Original EN: 01485878-01485911

ចូលអានដោយមិនគិតថ្លៃ ទាក់ទងនឹងកិច្ចដំណើរការនីតិវិធី និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេ ណីនៅ អ.វ.ត.ក។ ពិធីសាធារណៈមួយចំនួននឹងត្រូវរៀបចំធ្វើឡើង ដើម្បីលើកកម្ពស់ការយល់ដឹង អំពីប្រវត្តិសាស្ត្រនៃកម្ពុជាប្រជាធិបតេយ្យ តាមរយៈបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ បញ្ជីឈ្មោះពេញលេញ និងសក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ និងឯកសារសាធារណៈ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ[78]។

48. គម្រោងនេះផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការផ្តល់លទ្ធភាពឲ្យចូលមើលកំណត់ហេតុតុលាការស្តីពីការកាត់សេចក្តីខ្មែរក្រហម និងការសម្រួលចំពោះការចូលមើល និងការផ្សព្វផ្សាយឯកសារដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារសាធារណៈរបស់តុលាការដល់សាធារណជន និងមនុស្សជំនាន់ក្រោយ ស្របនឹងសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការពេញចិត្ត និងយុត្តិធម៌ ដូចមានចែងនៅក្នុងគោលការណ៍ជាមូលដ្ឋានស្តីពីដំណោះស្រាយ និងសំណង ដោយផ្តល់ប្រយោជន៍ផងដែរដល់ជនរងគ្រោះជាច្រើនដែលពុំមានតំណាង។ កាលពីថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៦ នាយកមជ្ឈមណ្ឌលត្រូវបានអញ្ជើញឲ្យធ្វើបទបង្ហាញអំពីគម្រោងនេះទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៣០នាក់ នៅវេទិកាដើមបណ្តឹងរដ្ឋប្បវេណី និងបានទទួលយកមតិយោបល់របស់ពួកគាត់។ កាលពីថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៧ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអញ្ជើញមកកាន់មជ្ឈមណ្ឌល ដើម្បីចូលរួមវេទិកាដើមបណ្តឹងរដ្ឋប្បវេណី ដោយពួកគាត់ត្រូវបានផ្តល់ឱកាសទស្សនាមជ្ឈមណ្ឌលនោះ និងត្រូវបានជម្រាបជូនអំពីសកម្មភាពគម្រោង។

49. គម្រោងនេះបានទទួលការឧបត្ថម្ភថវិកាទាំងស្រុងពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈថវិកាជាតិ[79]។ អគារមជ្ឈមណ្ឌលត្រូវបានសាងសង់រួចហើយ តាមរយៈថវិកាឧបត្ថម្ភដោយស្ថានទូតជប៉ុន[80]។

---

កម្ពុជា ពាក់ព័ន្ធនឹងគម្រោងសំណងចំពោះដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០២, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦, **E352/2/1.2. 1**។ ឧបសម្ព័ន្ធ ៣៖ គម្រោងត្រូវបានចាត់ជាអាទិភាព (គម្រោងទី៣), **E352/2/1.2.3**។

[78] ឧបសម្ព័ន្ធទី ១០៖ការចូលមើលកំណត់ហេតុតុលាការស្តីពីការកាត់សេចក្តីខ្មែរក្រហម និងសម្ភារៈរបស់ដើមបណ្តឹង រដ្ឋប្បវេណីនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធ អ.វ.ត.ក (LDC), ទិដ្ឋភាពរួមអំពីគម្រោងសំណង។

[79] ឧបសម្ព័ន្ធទី ១០.៤ ៖ការចូលមើលកំណត់ហេតុតុលាការស្តីពីការកាត់សេចក្តីខ្មែរក្រហម និងសម្ភារៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធ អ.វ.ត.ក (LDC), ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, *អនុក្រិត្យបណ្តឹងទាមទារចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណង នៅក្នុងសំណុំរឿង ០០២/០២ ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់*

## ឃ. ការស្ដារនីតិសម្បទា

50. វិធានការសំណងនៃការស្ដារនីតិសម្បទា រួមមានការផ្ដល់ការថែទាំវេជ្ជសាស្ត្រ និងចិត្តសាស្ត្រ[81]។ ដើមបណ្ដឹងរដ្ឋប្បវេណីតែងបញ្ជាក់ថា ការទទួលបានសេវាសុខភាពផ្លូវចិត្ត និងផ្លូវកាយ ស្ថិតក្នុងចំណោមបញ្ហាជាសំខាន់ៗរបស់ពួកគាត់។ ដូចបានបង្ហាញនៅក្នុងផ្នែកស្ដីពីព្យសនកម្ម បន្ទាប់ពីជំពូកនីមួយៗនៅក្នុងផ្នែកទី ៤ នៃសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល[82] ដើមបណ្ដឹងរដ្ឋប្បវេ

---

*ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធ អ.វ.ត.ក* (អនុក្រិត្យលេខ ១៥៩ អនក្រ.បក), មាត្រា ៤។

[80] ឧបសម្ព័ន្ធទី ១០.៤ ៖ការចូលមើលកំណត់ហេតុតុលាការស្ដីពីការកាត់សេចក្ដីខ្មែរក្រហម និងសម្ភារៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធ អ.វ.ត.ក (LDC), ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ។

[81] គោលការណ៍ និងគោលការណ៍ណែនាំជាមូលដ្ឋានស្ដីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភដ៏កម្រោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ, សេចក្ដីសម្រេចលេខ ៦០/១៤៧,មហាសន្និបាតអង្គការសហប្រជាជាតិ, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥, មាត្រា២២។

[82] *សូមមើល ឧទាហរណ៍* ប្រតិចារឹកនៃការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អៀម យេន, ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥, **E1/286.1, [**កែតម្រូវ២**]** ,ទំព័រ៦៤, បន្ទាត់ទី៩ ដល់១០ (“សុខភាព ក៏មិនមាំមួនអីដែរ ព្រោះអីកាលនោះនៅក្មេងកុមារតូចប្រើធ្វើការហួសកម្លាំង”)។ ប្រតិចារឹកនៃការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម សារឿន, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥, **E1/283.1, [**កែតម្រូវ១**]** ,ទំព័រ១៩, បន្ទាត់ទី២១ ដល់២៣ (“ខ្ញុំ ចាសនាងខ្ញុំនិយាយកាលខ្ញុំមកដាក់ពាក្យ។ ខ្ញុំៗសម្រាន្តមិនលក់ ឈឺក្បាលរសេះរសោះ ហើយថប់ៗទ្រូង ខ្ញុំគិតរឿងហ្នឹងចេះតែរឿងថ្មី”។ “ខ្ញុំចងចាំឥឡូវ ខ្ញុំអត់ភ្លេចភ្លាំងទេ អារម្មណ៍ខ្ញុំឥឡូវសម្រាន្តស្រួល។ ខ្ញុំបានថ្នាំពី ធី.ភី.អូ ខ្ញុំអត់សូវចងចាំ បើកថ្នាំហ្នឹង លេប អារម្មណ៍ខ្ញុំស្រួល ឥឡូវហ្នឹងស្រួល អត់មានភ្លេចភ្លាំង នឹកឃើញរឿងដើម”)។ ប្រតិចារឹកនៃការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម សារឿន, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥, **E1/283.1, [**កែតម្រូវ១**]** ,ទំព័រ២២, បន្ទាត់ទី៥ ដល់១១ (“យកខ្ញុំទៅដាក់សេរ៉ូម ឲ្យលេបថ្នាំៗគ្រាប់ដូចធ្វើជាដំឡូងមី ហើយសេរ៉ូមជាទឹកដូងយកស្រស់ យកទៅ យកដាក់ជើងខ្ញុំហ្នឹងខូចដើរទៅខ្ញើកៗទល់សព្វថ្ងៃនៅឈឺដែរ។ នាងខ្ញុំបានតានោះគាត់ប្រាប់ថា តែទុកស្វិតជើងហើយ គាត់ឲ្យរកអង្រ្គង ពន្លៃ ស្រា ឲ្យសុំមេស្រាយកមកស្អំរឹតទៅ”។ ប្រតិចារឹកនៃការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សុក្ខានី, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥, **E1/306.1, [**កែតម្រូវ១**]** ,ទំព័រ៥, បន្ទាត់ទី១២ ដល់១៤ និងទំព័រ៨២, បន្ទាត់ទី៤ ដល់៦, និងបន្ទាត់ទី១៦ (“រែកដីតិចខ្លាចចាញ់គេ អីចឹងខំដាក់ពេញៗបង្គី ខ្លាចចាញ់ភូមិគេ ខ្លាចអង្គការមើលមិនឃើញ។ ឈឺចុកចង្កេះចុកខ្នង ខ្ញុំចុកតាំងពីក្មេង តាំងពីជំនាន់រែកដីរហូតដល់សព្វថ្ងៃហ្នឹង ប្រឹងដើម្បីអី ប្រឹងដើម្បីរស់ ខំដើម្បីរស់។” “ខ្ញុំបាត់បង់គ្មានសល់ ទុក្ខលំបាកដែលខ្ញុំមិនធ្លាប់ស្គាល់ គឺខ្ញុំស្គាល់អស់ហើយ។ ភាពឯកោហ្នឹងយ៉ាងណា អ្នកណាដែលឯកោដូចខ្ញុំ អ្នកនោះនឹងដឹងអ្នកដែលគេមិនឯកោ គឺគេមិនដឹងទេ”។ **[…]** “ខ្ញុំខ្លាចមែនទែន ខ្ញុំបាក់ស្បាតអស់ហើយ”)។ ប្រតិចារឹកនៃការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សុក្ខានី, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥, **E1/318.1, [**កែតម្រូវ២**]** ,ទំព័រ៩២,

---

បន្ទាត់ទី៥ ដល់១៣ (“ខ្ញុំខំប្រឹងលីៗមិនរួច ខ្ញុំដើរទា គេថាឲ្យខ្ញុំទៀត គេថាមិត្តឯងអីក៏លីមិនរួច ក៏កម្លាំងអីក៏លីមិនរួច។ រហូតដល់ខ្ញុំលីស៊ីម៉ង់ត៍ ខ្ញុំជីកដីហើយ សព្វថ្ងៃក៏ប៉ះពាល់ដល់រាងកាយរបស់ខ្ញុំនេះឈឺដើមទ្រូងខ្ញុំនៅរាល់ថ្ងៃ ហើយចង្កេះខ្ញុំគឺគ្រាំគ្រារាល់ថ្ងៃ ទោះបីខ្ញុំមកសាលាក្តីកន្លែងនេះក៏ខ្ញុំលេបថ្នាំដែរ ខ្ញុំលេបថ្នាំឡើងឈាម ខ្ញុំលេបថ្នាំសរសៃបានខ្ញុំដើររួចបានប៉ុណ្ណេះ”)។ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត, ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥, **E1/364.1, [**កែតម្រូវ១**]** ,ទំព័រ១៣, បន្ទាត់ទី២២ ដល់២៤ និងទំព័រ១៤, បន្ទាត់ទី៣ ដល់៤ (“ការខ្ញុំធ្វើការខ្លាំង ធ្ងន់ធ្ងរហត់ វាឡើងតឹងសរសៃកខ្ញុំ តែងតែម្តង រឹងសរសៃក ហើយវិលមុខតែម្តង អត់ឃើញអី ងងឹតបណ្តោយ។” “បញ្ហាហ្នឹងខ្ញុំត្រូវបីខ្នងពូថៅហ្នឹងហើយ។ រឿងបញ្ហាអីចឹងតែម្តង។”)។ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ថី , ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦, **E1/393.1, [**កែតម្រូវ១**]** ,ទំព័រ៩៨, បន្ទាត់ទី៥ ដល់ទំព័រ១០០, បន្ទាត់ទី១៧ (“នៅពេលដែលខ្ញុំថ្លែងទុក្ខប្រាប់អស់លោកទាំងអស់គ្នាស្តាប់ ប្រៀបដូចជារឿងហ្នឹងនៅថ្មី នៅមុខខ្ញុំប្រៀបដូចជាខ្សែវីដេអូមួយដែលចាក់បញ្ចាំងរឿងឈឺចាប់ទាំងប៉ុន្មាន ដែលខ្ញុំបានឆ្លងកាត់ពីជំនាន់ ប៉ុល ពត មក ដែលខ្ញុំព្រាត់ប្រាសឪពុកជាទីស្រឡាញ់បងប្រុសទាំងពីររបស់ខ្ញុំដែលគេធ្វើទារុណកម្ម”)។ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ , ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦, **E1/394.1, [**កែតម្រូវ២**]** ,ទំព័រ១០០, បន្ទាត់ទី៥ ដល់១៩ (“ខ្ញុំមានក្តីអស់សង្ឃឹមរលីងអស់។ ម៉េចបានអស់ក្តីសង្ឃឹម? ពីព្រោះក្រុមគ្រួសារដែលជាបង្អែករបស់ខ្លួនស្លាប់បាត់បង់ជីវិត។ ឪពុកលោកអ្នកដែលមានគុណក៏ស្លាប់បាត់បង់ជីវិតដែរ។ដឹងថាតែបាត់ខ្លួន គឺស្លាប់ហ្នឹងហ្មង។ ហើយឪពុកក្មេក ក៏អស់។ ដូច្នេះ ពេលខ្លះ ខ្ញុំនឹកថាអាត្មាអញគួរតែសម្លាប់ខ្លួនតាមទៅ ដើម្បីឲ្យវិញ្ញាណក្ខន្ធជាតិក្រោយ បានជួបគ្នា ឬយ៉ាងម៉េច ប៉ុន្តែនឹកឃើញដល់ពាក្យសុភាសិតបារាំងដែលបានធ្លាប់រៀនសូត្រ យល់ដឹងកន្លងមក ថាជីវិតគឺជាការតស៊ូ ជីវិតជាការតស៊ូ ត្រូវតែតស៊ូ ទោះបីខ្លួនឯងបាន មិនបានកើតមិនកើត សម្រេច មិនសម្រេច ជោគជ័យ [redacted]នជោគជ័យក៏ដោយ ក៏នៅចេះតែទ្រាំអីចឹងទៅ ទ្រាំមើលជីវិតហ្នឹង”)។ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន , ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦, **E1/381.1, [**កែតម្រូវ២**]** ,ទំព័រ៧០, បន្ទាត់ទី១០ ដល់១៣ និងទំព័រ៧២, បន្ទាត់ទី៨ ដល់១១ (“គេធ្វើបាបខ្ញុំឲ្យខ្ញុំរែកដីឲ្យខ្ញុំលីសែង ដកស្ទូង ធ្វើបាបខ្ញុំ ឥឡូវខ្ញុំឈឺពេញខ្លួនទាំងអស់ តាំងពីនុងមកដល់ហ្នឹង ព្រោះខ្ញុំធ្វើការធ្ងន់ៗពេក។ ទៅដល់ចាស់ទៅទ្រុឌទ្រោមដែរ”។ “ថាបន្ថែម មិនដឹងឲ្យវាជួយខ្ញុំខ្លះផង ព្រោះខ្ញុំក្រីក្រណាស់សព្វថ្ងៃ។ បានព្រឹកខ្វះល្ងាច បានល្ងាចខ្វះព្រឹក។ ចាស់ហើយទៅរកអី? ទៅលក់ដូរអី មិនកើតទេ ដើរតែខ្លួនមិនរួច” )។ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1040, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦, **E1/459.1,** ទំព័រ៩២, បន្ទាត់ទី១៣ ដល់២៥ (“ចង់ខ្ញុំយកចាប់បានចងយកទៅបាញ់ចោលនេះ ដែលធ្វើឲ្យខ្ញុំត្រូវរបួសពិការភាព បាក់ដៃរហូត ដែលខ្ញុំដើរព្យាបាលតាមពេទ្យឯកជន តាមពេទ្យរដ្ឋ បាត់បង់កម្លាំងពលកម្ម ការរកទទួលទានមិនកើត”)។ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី [redacted] , ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៧, **E1/418.1,** ទំព័រ២០, បន្ទាត់ទី១៤ ដល់១៨ និង ទំព័រ៤៧, បន្ទាត់ទី១៧ ដល់២០ (“វាពិបាកនោះ បញ្ហាពិបាកៗហើយ ព្រោះទី១ គឺកម្រិតវប្បធម៌ខ្ញុំ វាមិនបានខ្ពង់ខ្ពស់ទេ ហើយពេលឥឡូវនេះ គឺថាភ្នែករបស់ខ្ញុំក៏អត់បានភ្លឺច្បាស់ដែរ ដោយសារគេដាក់ខ្សែភ្លើង អាភ្នែកខាងនេះប្រើអត់កើតទេ។” “ម្ខាងហ្នឹងឥឡូវប្រើការអត់កើតទេលោកប្រធានអត់បានទេ។ គោះអីចឹង ដូចទឹកចូលអីចឹង ទឹងៗ បាទ ហើយបិទម្ខាងនេះស្រែកម៉េចក៏អត់ឮដែរ។ អាពេលហ្នឹងដែលខ្ញុំឃើញនេះអីចឹង គឺថាខ្ញុំមានតែស្លាប់តែម្តង ពីព្រោះខ្ញុំអត់ដឹងខ្លួនទាល់តែសោះ”)។

ណី បានលើកឡើងអំពីបំណងរបស់ខ្លួនក្នុងការទទួលបានការថែទាំសុខភាពផ្លូវចិត្ត និងផ្លូវកាយ ដែលជាផលវិបាកនៃឧក្រិដ្ឋកម្មដែលបានជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២។

51. សហមេធាវីនាំមុខយល់ឃើញថា គម្រោងនេះមានផលប៉ះពាល់ទៅលើវិធានការសំណងនៃការស្តារនីតិសម្បទា និងផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះព្យសនកម្មដែលបានទទួលរងដោយសារបទឧក្រិដ្ឋដែលបានចោទនៅក្នុងសំណុំរឿង០០២/០២ និងស្នើឱ្យអង្គជំនុំជម្រះអនុម័តគម្រោងនេះថាជាការអនុវត្តសំណងតុលាការ។

**(១១) ការព្យាបាល និងការផ្សះផ្សាសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម**

52. អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) បានបង្កើតគម្រោងសំណងដែលបានស្នើឡើងនេះ គឺ "ការព្យាបាល និងការផ្សះផ្សាសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម"[83] ដោយសហការជាមួយអង្គការក្តីករុណា និងដោយមានការគាំទ្រពីសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ។ គម្រោងនេះផ្តល់ការព្យាបាលការប៉ះទង្គិចផ្លូវចិត្តដល់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងខេត្តចំនួន ១៥[84]។ គម្រោងនេះនឹង (១) ផ្តល់សេវាសុខភាពផ្លូវចិត្ត (២) ផ្តល់ការអន្តរាគមន៍តាមរយៈវេទិកានៃការនិយាយពីការពិត និងផ្សះផ្សា និង (៣) ផ្តល់ការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិកគម្រោង និងអ្នកសម្របសម្រួលនៅមូលដ្ឋាននៅក្នុងសហគមន៍គោលដៅនីមួយៗ។ ការព្យាបាលការប៉ះទង្គិចផ្លូវចិត្ត រួមមាន ការផ្តល់ប្រឹក្សាដោយផ្ទាល់ដល់កន្លែង និងតាមទូរស័ព្ទ ក្រុមជួយខ្លួនឯង និងវិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម។ ការថ្លែងពីការពិត និងសកម្មភាពផ្សះផ្សា (រួមមានការសន្ទនាក្នុងសហគមន៍ ការផ្តួចផ្តើមរំឭកចងចាំ/វេទិកាមហោស្រព

---

[83] ឧបសម្ព័ន្ធទី១១៖ ការព្យាបាល និងការផ្សះផ្សាសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ *សូមមើលផងដែរ* របាយការណ៍បណ្តោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណងនៅក្នុងសំណុំរឿង០០២/០២ និងសំណើពាក់ព័ន្ធ, **E352**, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ១៩ និងឧបសម្ព័ន្ធសម្ងាត់ទី១ (គម្រោងទី២), **E352.2** ។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង០០២/០២, **E352/2/1**, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ១៣ និងឧបសម្ព័ន្ធ ២៖ គម្រោងស្ថិតក្រោមការពិចារណា (គម្រោងទី៤), **E352/2/1.2.2**។

[84] កំពង់ឆ្នាំង, បាត់ដំបង, កំពង់ធំ, កណ្តាល, កែប, កំពត, តាកែវ, ព្រៃវែង, ស្វាយរៀង, ត្បូងឃ្មុំ, កំពង់ចាម, សៀមរាប, ក្រចេះ និងមណ្ឌលគិរី។

និងសកម្មភាពផ្សព្វផ្សាយដល់យុវជន) មានគោលដៅអប់រំ និងបង្កើនការអាណិតអាសូរដល់អ្នករស់រានមានជីវិតពីការធ្វើទារុណកម្ម[85]។ គម្រោងនេះនឹងត្រូវអនុវត្តសម្រាប់រយៈពេលបីឆ្នាំ ចាប់ពីខែ ឧសភា ឆ្នាំ ២០១៦ និងបញ្ចប់ក្នុងខែ សីហា ឆ្នាំ ២០១៩។

53. គម្រោងនេះនឹងផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលរងការធ្វើទារុណកម្ម រួមមាន ជនជាតិចាម អ្នករស់រានមានជីវិតពីអំពើហិង្សាផ្នែកយេនឌ័រ និងអ្នករស់រានមានជីវិតពីការធ្វើពលកម្មដោយបង្ខំ។ ជាឧទាហរណ៍ ហើយត្រូវបានពិពណ៌នាលម្អិតក្នុងឧបសម្ព័ន្ធ ១១.២ ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រហែល ៤៥នាក់ នឹងទទួលប្រយោជន៍ពីក្រុមជួយខ្លួនឯង[86]។ អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) បានបង្ហាញគម្រោងនេះទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៥០នាក់ នៅវេទិកាដើមបណ្តឹងរដ្ឋប្បវេណីមួយ ដែលបានធ្វើឡើងនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធ កាលពីថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៧។

54. គម្រោងនេះបានទទួលការឧបត្ថម្ភថវិកាទាំងស្រុងពី USAID[87]។

## III. គម្រោងដែលបានទទួលការឧបត្ថម្ភថវិកាពេញលេញ និងគាំទ្រដោយសហមេធាវីនាំមុខអន្តរជាតិ

55. សហមេធាវីនាំមុខអន្តរជាតិយល់ឃើញថា គម្រោងខាងក្រោមនេះផ្តល់ផលប៉ះពាល់ទៅដល់វិធានការសំណងនៃការធានាមិនឲ្យកើតឡើងជាថ្មីនូវអំពើឧក្រិដ្ឋកម្ម និងឆ្លើយតបទៅនឹងព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិចវៀតណាមបានទទួលរង[88]។ សហមេធាវីនាំមុខ

---

[85] ឧបសម្ព័ន្ធទី១១.២៖ ការព្យាបាល និងការផ្សះផ្សាសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, ទិដ្ឋភាពរួមអំពីគម្រោងសំណង។

[86] ឧបសម្ព័ន្ធទី១១.២៖ ការព្យាបាល និងការផ្សះផ្សាសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, ទិដ្ឋភាពរួមអំពីគម្រោងសំណង។

[87] ឧបសម្ព័ន្ធទី១១.២៖ ការព្យាបាល និងការផ្សះផ្សាសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, ទិដ្ឋភាពរួមអំពីគម្រោងសំណង, ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, លិខិតពី USAID។

[88] *សូមមើល,* សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង០០២/០២, E352/2/1, ឧបសម្ព័ន្ធ ២៖ គម្រោងស្ថិតក្រោមការពិចារណា (គម្រោងទី៩), E352/2/1.2.2។ សូមមើលផងដែរ ប្រតិចារឹកនៃការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំងថេង, ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ *បណ្តឹងទាមទារចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណង នៅក្នុងសំណុំរឿង ០០២/០២ ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់*

អន្តរជាតិស្នើឲ្យអង្គជំនុំជម្រះពិចារណាលើគម្រោងនេះ និងអនុម័តលើគម្រោងនេះថាជាការផ្ដល់សំណងតុលាការក្នុងសំណុំរឿង០០២/០២។

## (១២) ការអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្ដឹងរដ្ឋប្បវេណីជាជនជាតិភាគតិច

56. អង្គការការពារសិទ្ធិជនជាតិភាគតិច (MIRO) បានរៀបចំបង្កើត និងអនុវត្តគម្រោង "ការអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្ដឹងរដ្ឋប្បវេណីជាជនជាតិភាគតិច" ដែលជាគម្រោងសំណងដែលបានស្នើឡើងមួយ ដែលផ្ដល់ការអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្ដឹងរដ្ឋប្បវេណី ក្រុមគ្រួសារ និងសហគមន៍របស់ពួកគាត់[89]។ គម្រោងនេះត្រូវបានអនុវត្តពេញលេញពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ ២០១៦ ដោយមានគម្រោងសាកល្បងមួយសម្រាប់ការអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋ ពិធីពិគ្រោះយោបល់សហគមន៍ និងការផលិតសម្ភារផ្សព្វផ្សាយជាភាសាដែលសហគមន៍អាចយល់បាន។ គម្រោងនេះក៏បានរៀបចំធ្វើសិក្ខាសាលាផ្សព្វផ្សាយ និងអប់រំនៅមូលដ្ឋានសហគមន៍ ដែលបានធ្វើឡើងនៅក្នុងសហគមន៍ដែលដើមបណ្ដឹងរដ្ឋប្បវេណីរស់នៅ[90]។

57. គម្រោងនេះផ្ដល់ប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណី តាមរយៈការបង្កើនការយល់ដឹងអំពីឋានៈផ្លូវច្បាប់របស់គាត់ តាមច្បាប់កម្ពុជា។ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប្រហែល ៣៩ នាក់ និងសមាជិកសហគមន៍ដែលបានទទួលរងការប្រព្រឹត្តិលើជនជាតិភាគតិចវៀតណាម ក្នុងអំឡុងរបប

---

២០១៥, **E1/393.1**, [កែតម្រូវ១], ទំព័រ២៧, បន្ទាត់ទី២ ដល់ទំព័រ៣ ("មុនចេញទៅវៀតណាម ផ្ទះយើងត្រូវបានដុតបំផ្លាញជាមួយនឹងសៀវភៅគ្រួសាររបស់យើង។ របស់របរទាំងអស់នៅនឹងផ្ទះ ដុតចោលអស់ហើយ នៅអីទៀត")។

[89] ឧបសម្ព័ន្ធទី១២៖ ការអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្ដឹងរដ្ឋប្បវេណីជាជនជាតិភាគតិច។ *សូមមើលផងដែរ* របាយការណ៍បណ្ដោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីសំណងនៅក្នុងសំណុំរឿង០០២/០២ និងសំណើពាក់ព័ន្ធ, **E352**, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ២១ និងឧបសម្ព័ន្ធសម្ងាត់ទី១ (គម្រោងទី១៨), **E352.2** ។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង០០២/០២, **E352/2/1**, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ១៣ និងឧបសម្ព័ន្ធ ២៖ គម្រោងស្ថិតក្រោមការពិចារណា (គម្រោងទី៩), **E352/2/1.2.2**។

[90] ឧបសម្ព័ន្ធទី១២.២៖ ការអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្ដឹងរដ្ឋប្បវេណីជាជនជាតិភាគតិច, ទិដ្ឋភាពរួមអំពីគម្រោងសំណង។ ឧបសម្ព័ន្ធទី១២.២៖ ការអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្ដឹងរដ្ឋប្បវេណីជាជនជាតិភាគតិច, ទិដ្ឋភាពរួមអំពីគម្រោងសំណង, របាយការណ៍បញ្ចប់ស្ដីពីការអនុវត្តគម្រោងសំណងសមូហភាពដែលបានស្នើឡើងនៅក្នុងសំណុំរឿង ០០២/០២។

កម្ពុជាប្រជាធិបតេយ្យ ត្រូវបានពិគ្រោះយោបល់នៅក្នុងខេត្តកំពង់ឆ្នាំង ក្នុងខែ សីហា ឆ្នាំ ២០១៥ អំពីគម្រោងនេះ និងទទួលបានការឧបត្ថម្ភបន្ថែមទៀតសម្រាប់ការវិវត្តន៍ទៅមុខ។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៩ នាក់ បានចូលរួម និងទទួលប្រយោជន៍ដោយផ្ទាល់ពីសកម្មភាពគម្រោងនៅក្នុងទីតាំងចំនួនបី។ សមាជិកគ្រួសារ និងសហគមន៍ដែលមានចំនួនជាង ៦០នាក់ ក៏បានចូលរួមក្នុងគម្រោងនេះដែរ។ លទ្ធផលនៃគម្រោងនេះផ្តល់ប្រយោជន៍ដោយប្រយោលដល់សហគមន៍ទូទៅនៃជនជាតិភាគតិចវៀតណាមដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅក្នុងខេត្តកំពង់ឆ្នាំង និងខេត្តផ្សេងទៀត ដែលទទួលរងព្យសនកម្មស្រដៀងគ្នាទៅនឹងព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/២ បានទទួលរង[91]។

58. គម្រោងនេះបានទទួលការឧបត្ថម្ភទាំងស្រុងពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធសហព័ន្ធអាល្លឺម៉ង់ តាមរយៈសេវាសន្តិភាពសម្រាប់ពលរដ្ឋ (ZFD) នៃ Deutschen Gesellschaft für Internationale Zusammenarbeit (GIZ) GbmH [92]។

## IV. គម្រោងដែលពុំបានទទួលការឧបត្ថម្ភថវិកាពេញលេញ

59. សហមេធាវីនាំមុខស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាលើគម្រោងចំនួន ៤ ក្រោមលក្ខខណ្ឌថា គម្រោងទាំងនេះទទួលបានថវិកាពេញលេញ ត្រឹមថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៧[93]។ ប្រសិនបើអង្គជំនុំសាលាដំបូងច្រានចោលសំណើសុំពន្យារពេល សហមេធាវីនាំមុខនឹងដកគម្រោងនេះចេញពីការស្នើសុំការពិចារណា។ ប្រសិនបើសំណុំសុំពន្យារពេលត្រូវបានទទួលយក ហើយពុំមានព័ត៌មានបន្ថែមទាក់ទងនឹងស្ថានភាពថវិកាទេនោះ សហមេធាវីនាំមុខក៏នឹងដកគម្រោងនេះចេញពីការស្នើសុំការពិចារណាផងដែរ។

---

[91] ឧបសម្ព័ន្ធទី១២.២៖ ការអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិច, ទិដ្ឋភាពរួមអំពីគម្រោងសំណង, របាយការណ៍បញ្ចប់ស្តីពីការអនុវត្តគម្រោងសំណងសមូហភាពដែលបានស្នើឡើងនៅក្នុងសំណុំរឿង ០០២/០២។

[92] ឧបសម្ព័ន្ធទី១២.៥៖ ការអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិច, ទិដ្ឋភាពរួមអំពីគម្រោងសំណង, ការផ្ទៀងផ្ទាត់អំពីការធានាផ្នែកមូលនិធិ, កិច្ចព្រមព្រៀង រវាង GIZ និង MIRO។

[93] សូមមើល *ដូចខាងលើ*, កថាខណ្ឌ ១៣។

### (១៣) គម្រោងលើកកម្ពស់សុខភាព និងសុខុមាលភាពផ្លូវចិត្ត និងកាត់បន្ថយហានិភ័យនៃភាពក្រីក្រ និងការកាត់ផ្តាច់ពីសង្គមនៃដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងបុគ្គលចាស់ជរាដែលងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា

60. អង្គការ HelpAge កម្ពុជា ដោយមានការគាំទ្រពីសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានបង្កើត "គម្រោងលើកកម្ពស់សុខភាព និងសុខុមាលភាពផ្លូវចិត្ត និងកាត់បន្ថយហានិយភ័យនៃភាពក្រីក្រ និងការកាត់ផ្តាច់ពីសង្គមនៃដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងបុគ្គលចាស់ជរាដែលងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា" ដែលជាគម្រោងសំណងមួយសម្រាប់ជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី[94]។ គម្រោងនេះព្យាយាមជួយដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានវ័យចំណាស់ តាមរយៈការបង្កើនការទទួលបានសេវាថែទាំសុខភាពផ្លូវកាយ និងផ្លូវចិត្ត ដោយបង្កើតកន្លែងផ្តល់សេវាសុខភាពចល័ត ដើម្បីផ្តល់ការថែទាំ និងការពិនិត្យសុខភាពបឋមជាមូលដ្ឋាន និងដើម្បីផ្តល់ការអប់រំសុខភាពផ្លូវចិត្តនៅថ្នាក់សហគមន៍។ គម្រោងនេះក៏ប្រឹងប្រែងបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល និងអ្នកស្ម័គ្រចិត្ត និងពង្រីកសមត្ថភាពបណ្តាញសមាគមមនុស្សចាស់ ដើម្បីឈានទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី និងសហគមន៍គោលដៅ។ គម្រោងនេះត្រូវបានរំពឹងថាមានរយៈពេល ២,៥ ឆ្នាំ[95]។

61. គម្រោងនេះនឹងផ្តល់ប្រយោជន៍ប្រកបដោយអត្ថន័យដល់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការបង្កើនការទទួលបានការថែទាំសុខភាព ដោយផ្តោតជាពិសេសទៅលើព្យសនកម្មផ្លូវកាយ និងផ្លូវ

---

[94] ឧបសម្ព័ន្ធទី ១៣ ៖ គម្រោងលើកកម្ពស់សុខភាព និងសុខមាលភាពផ្លូវចិត្ត និងកាត់បន្ថយហានិយភ័យនៃភាពក្រីក្រ និងការកាត់ផ្តាច់ពីសង្គមនៃដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងបុគ្គលចាស់ជរាដែលងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា។ *សូមមើលផងដែរ,* របាយការណ៍បណ្តោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណង នៅក្នុងសំណុំរឿង ០០២/០២ និងសំណើពាក់ព័ន្ធ, E352, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ១ និងឧបសម្ព័ន្ធសម្ងាត់ទី១ (គម្រោងទី១), E352.2, សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង០០២/០២, E352/2/1, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ ៤៥-៤៧ និងឧបសម្ព័ន្ធទី៣៖ គម្រោងជាអាទិភាព (គម្រោងទី៩), E352/2/1.2.3។

[95] ឧបសម្ព័ន្ធទី ១៣.២ ៖ គម្រោងលើកកម្ពស់សុខភាព និងសុខមាលភាពផ្លូវចិត្ត និងកាត់បន្ថយហានិយភ័យនៃភាពក្រីក្រ និងការកាត់ផ្តាច់ពីសង្គមនៃដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងបុគ្គលចាស់ជរាដែលងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា, ទិដ្ឋភាពរួមអំពីគម្រោងសំណង។

ចិត្ត ដែលដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានទទួលរងដោយសារបទឧក្រិដ្ឋនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២[96]។ គម្រោងនេះទទួលបានការគាំទ្រយ៉ាងខ្លាំងក្លាពីដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងកិច្ចពិគ្រោះយោបល់ ជាពិសេសនៅពេលដែលអង្គការ HelpAge កម្ពុជា បង្ហាញគម្រោងនេះដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១១០នាក់ និងទទួលបានមតិយោបល់របស់ពួកគាត់ កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៦ ក្នុងអំឡុងវេទិកាដើមបណ្តឹងរដ្ឋប្បវេណីមួយ។ កាលពីថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៦ អង្គការ HelpAge ត្រូវបានអញ្ជើញឱ្យធ្វើបទបង្ហាញអំពីគម្រោងនេះដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៣០ នាក់ នៅវេទិកាដើមបណ្តឹងរដ្ឋប្បវេណីមួយ និងទទួលបានយោបល់របស់ពួកគាត់អំពីគម្រោង។ សេវាសន្តិភាពសម្រាប់ពលរដ្ឋ/Forum Ziviler Frieddens dienst e.V. (forumZFD) បានរៀបចំកិច្ចពិគ្រោះយោបល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៣ នាក់ នៅបាត់ដំបង ដែលក្នុងវេទិកានោះ អង្គការ HelpAge បានបង្ហាញអំពីគម្រោងនេះដល់ដើមបណ្តឹងរដ្ឋប្បវេណី និងទទួលបានមតិយោបល់ស្តីពីគម្រោងនេះ។

62. គម្រោងនេះពុំទទួលបានការឧបត្ថម្ភថវិកានៅឡើយ។

### (១៤) វេទិកាអប់រំជាសាធារណៈ និងការតាំងពិពណ៌ជាអចិន្ត្រៃយ៍អំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ

63. មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានរៀបចំបង្កើតគម្រោង "វេទិកាអប់រំជាសាធារណៈ និងការតាំងពិពណ៌ជាអចិន្ត្រៃយ៍អំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ" ដែលជាគម្រោងសំណងដែលបានស្នើឡើងក្នុងសំណុំរឿង ០០២/០២[97]។ គម្រោងនេះនឹងបង្កើតឱ្យមានការតាំងពិពណ៌ជាអចិន្ត្រៃយ៍ និងចល័តអំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមនៅក្នុងខេត្តចំនួន ៥ និងផ្តោតលើដំណើររឿងប្រវត្តិសាស្ត្រអំពីទីកន្លែងឧក្រិដ្ឋកម្មដែលបានចោទនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២។ គម្រោងនេះក៏ព្យាយាម

---

[96] សូមមើល *ដូចខាងលើ*, កំណត់សម្គាល់ ៨២។

[97] ឧបសម្ព័ន្ធទី១៤៖ វេទិកាអប់រំជាសាធារណៈ និងការតាំងពិពណ៌ជាអចិន្ត្រៃយ៍អំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ។ *សូមមើលផងដែរ* សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង០០២/០២, E352/2/1, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ១៣ និងឧបសម្ព័ន្ធ ២៖ គម្រោងស្ថិតក្រោមការពិចារណា (គម្រោងទី៦), E352/2/1.2.2។

ដាក់បញ្ចូលបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ រួមទាំងជនជាតិចាម និងជនជាតិភាគតិចផ្សេងទៀតណាម។ សៀវភៅពិពណ៌នាអំពីការតាំងពិពណ៌ នឹងត្រូវផលិត និងបោះពុម្ពផ្សាយផងដែរ ដើម្បីរក្សាឯកសារនៃការតាំងពិពណ៌ និងពង្រីកព័ត៌មានទាក់ទងនឹងបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ សៀវភៅពិពណ៌នានេះនឹងត្រូវបោះពុម្ពផ្សាយជាភាសាខ្មែរ និងអង់គ្លេស ដើម្បីផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់អ្នកអាន។ គម្រោងនេះនឹងរៀបចំធ្វើសិក្ខាសាលាអប់រំជាសាធារណៈចំនួន ២៥ លើក នៅក្នុងខេត្តចំនួន ២៥ ផងដែរ ដែលនឹងត្រូវដឹកនាំដោយគ្រូបង្រៀនមុខវិជ្ជាប្រវត្តិសាស្ត្រនៅមូលដ្ឋានចំនួនបីនាក់ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដើមបណ្តឹងរដ្ឋប្បវេណី សិស្សានុសិស្ស អ្នកភូមិ និងគ្រូបង្រៀនមុខវិជ្ជាប្រវត្តិសាស្ត្រ នឹងត្រូវបានអញ្ជើញឲ្យចូលរួមក្នុងវេទិកាទាំងនោះ។ ជាផ្នែកមួយនៃវេទិកាទាំងនោះ មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងចែកចាយសៀវភៅ *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩)* និងភ្ជាប់ឯកសារដែលជាសៀវភៅសិក្សានោះ ជាមួយនឹងរឿងរ៉ាវជាក់លាក់ទាក់ទងនឹងសហគមន៍នីមួយៗ និងដើមបណ្តឹងរដ្ឋប្បវេណី។ គម្រោងនេះមានរយៈពេលបីឆ្នាំ (២០១៦ ដល់ ២០១៨)[98]។ គម្រោងនេះទទួលបានការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា[99]។

64. ដើមបណ្តឹងរដ្ឋប្បវេណីនឹងទទួលប្រយោជន៍ពីគម្រោងនេះ តាមរយៈការដាក់បញ្ចូលសំឡេងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងសកម្មភាពប្រាប់រឿងរ៉ាវនានា និងទទួលប្រយោជន៍ពីការផ្តោតការយកចិត្តទុកដាក់របស់គម្រោងទៅលើការអប់រំសាធារណជនអំពីប្រធានបទ និងសេចក្តីសម្រេចរបស់ អ.វ.ត.ក តាមរយៈដំណើររឿងរបស់អ្នកនៅរស់រានមានជីវិត។ មជ្ឈមណ្ឌលឯកសារបានបង្ហាញគម្រោងទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៥០ នាក់នៅវេទិកាដើមបណ្តឹងរដ្ឋប្បវេណីដែលបានធ្វើឡើងនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធ អ.វ.ត.ក នៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ

---

[98] ឧបសម្ព័ន្ធទី១៤៖ វេទិកាអប់រំជាសាធារណៈ និងការតាំងពិពណ៌ជាអចិន្ត្រៃយ៍អំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ, ទិដ្ឋភាពរួមអំពីគម្រោងសំណង។

[99] ឧបសម្ព័ន្ធទី១៤៖ វេទិកាអប់រំជាសាធារណៈ និងការតាំងពិពណ៌ជាអចិន្ត្រៃយ៍អំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ, លិខិតពីក្រសួងអប់រំ យុវជន និងកីឡា។ ឧបសម្ព័ន្ធទី១៤.៤៖ វេទិកាអប់រំជាសាធារណៈ និងការតាំងពិពណ៌ជាអចិន្ត្រៃយ៍អំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ, លិខិតពីមន្ទីរអប់រំរាជធានី។

២០១៧។ តាមរយៈការតាំងពិពណ៌នានា និងសៀវភៅពិពណ៌នានេះ គម្រោងនេះក៏នឹងផ្តល់ប្រយោជន៍ផងដែរទៅដល់ជនរងគ្រោះជាច្រើនដែលពុំមានតំណាង។

65. គម្រោងនេះពុំទទួលបានការធានាថវិកានៅឡើយ។

**(១៥) ប្រជាជនជនជាតិដើមភាគតិចកម្ពុជា និងប៉ុល ពត**

66. សមាគមវប្បធម៌អាល្លឺម៉ង់កម្ពុជា សហការជាមួយសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានបង្កើត និងមានផែនការអនុវត្តគម្រោង "ប្រជាជនជនជាតិដើមនៅកម្ពុជា និងប៉ុល ពត" ជាគម្រោងសំណងតុលាការក្នុងសំណុំរឿង០០២/០២[100]។ គម្រោងនេះព្យាយាមផលិតខ្សែភាពយន្តឯកសារចំនួនបី និងវីដេអូនៃការផ្តល់សក្ខីកម្មមួយឈុតរបស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីបទពិសោធន៍របស់ជនជាតិដើមភាគតិចកម្ពុជាក្នុងអំឡុងរបបខ្មែរក្រហម។ ខ្សែភាពយន្តឯកសារ និងវីដេអូនឹងត្រូវផលិតដោយផលិតករភាពយន្ត និងនិស្សិតដែលជាជនជាតិដើមភាគតិច ដោយសហការយ៉ាងជិតស្និទ្ធជាមួយដើមបណ្តឹងរដ្ឋប្បវេណី។ ការដាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងវីដេអូ នឹងត្រូវធ្វើឡើងជាមួយនឹងការតាំងពិពណ៌រូបថត និងការសន្ទនាអន្តរជំនាន់។ គម្រោងនេះមានរយៈពេលមួយឆ្នាំ[101]។

67. គម្រោងនេះផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការផ្តល់ចំណេះដឹងដល់យុវជនដែលជាជនជាតិដើមភាគតិច និងជនជាតិភាគតិចកម្ពុជា និងតាមរយៈការផ្តល់វេទិកាសន្ទនាអន្តរជំនាន់។ គម្រោងនេះព្យាយាមធ្វើការជាមួយសហគមន៍ជនជាតិដើមភាគតិច ដើម្បីធានាបានការគាំទ្រយ៉ាងទូលំទូលាយពីសហគមន៍ និងដើម្បីជួយសម្រួលដល់ការសន្ទនាអន្តរជំនាន់។

---

[100] ឧបសម្ព័ន្ធទី១១៖ ប្រជាជនជនជាតិដើមភាគតិចកម្ពុជា និងប៉ុល ពត។ *សូមមើលផងដែរ* របាយការណ៍បណ្តោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណងនៅក្នុងសំណុំរឿង០០២/០២ និងសំណើពាក់ព័ន្ធ, E352, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ២១ និងឧបសម្ព័ន្ធសម្ងាត់ទី១ (គម្រោងទី៤), E352.2 ។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង០០២/០២, E352/2/1, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ១៣ និងឧបសម្ព័ន្ធ ២៖ គម្រោងស្ថិតក្រោមការពិចារណា (គម្រោងទី៤), E352/2/1.2.2។

[101] ឧបសម្ព័ន្ធទី១៥៖ ប្រជាជនជនជាតិដើមភាគតិចកម្ពុជា និងប៉ុល ពត, ទិដ្ឋភាពរួមអំពីគម្រោងសំណង។

68. គម្រោងនេះពុំទាន់ទទួលបានការឧបត្ថម្ភថវិកានៅឡើយ។

### (១៨) ការចូលមើល និងការផ្សព្វផ្សាយបណ្ណសារច្បាប់ និងប្រវត្តិសាស្ត្រទាក់ទងនឹងខ្មែរក្រហម

69. មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការគាំទ្រពីសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានស្នើសុំឱ្យបង្កើតមជ្ឈមណ្ឌលធនធានអប់រំច្បាប់ និងប្រវត្តិសាស្ត្រ ជាផ្នែកមួយនៃគម្រោងសំណងដែលបានស្នើឡើង ដែលមានឈ្មោះថា "ការចូលមើល និងការផ្សព្វផ្សាយបណ្ណសារច្បាប់ និងប្រវត្តិសាស្ត្រទាក់ទងនឹងខ្មែរក្រហម"[102]។ មជ្ឈមណ្ឌលធនធានអប់រំនឹងដាក់កំណត់ត្រា និងសម្ភារឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងឯកសារដែលអាចចូលមើលជាសាធារណៈ ទាក់ទងនឹង អ.វ.ត.ក។ តាមគម្រោង មជ្ឈមណ្ឌលធនធានអប់រំនេះនឹងមានទីតាំងនៅបាត់ដំបង កំពង់ឆ្នាំង ក្រចេះ និងតាកែវ និងគ្របដណ្តប់ខេត្តមួយចំនួន។ មជ្ឈមណ្ឌលធនធានអប់រំនីមួយៗនឹងមានទំនាក់ទំនងជាមួយនឹងមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀននៅមូលដ្ឋានមួយចំនួន[103]។ មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀនទាំងនេះ ត្រូវបានដំណើរការដោយក្រសួងអប់រំ យុវជន និងកីឡា ដែលបានផ្តល់ការអនុញ្ញាតដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ឱ្យប្រើប្រាស់ទីតាំងសម្រាប់សកម្មភាពទាក់ទងនឹងការអប់រំ[104]។

70. លើសពីនេះទៀត គម្រោងនេះនឹងប្រើប្រាស់វេទិកាអប់រំចល័ត ដែលមានការចូលរួមពីគ្រូបង្រៀនមួយក្រុម ដែលមានសម្ភារអប់រំមួយកញ្ចប់ ដើម្បីផ្សព្វផ្សាយដល់សហគមន៍ ដែលពុំមានលទ្ធភាពចូលមើលឯកសារទាំងនោះ។ គម្រោងនេះក៏ផលិតសៀវភៅអំពីការចងចាំ ដែលកំណត់អត្តសញ្ញាណអ្នកដែលបានបាត់បង់ជីវិតក្នុងអំឡុងរបបខ្មែរក្រហម ហើយនឹងបង្កើតកម្មវិធីស្វែងរកគ្រួសារតាមប្រព័ន្ធអ៊ិនធ័រណិតសម្រាប់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី អ្នករស់រានមានជីវិត និងក្រុមគ្រួសាររបស់ពួកគេ ប្រើប្រាស់ដើម្បីស្វែងរកមនុស្សជាទីស្រឡាញ់របស់ខ្លួន។ តាមរយៈការអនុវត្ត

---

[102] ឧបសម្ព័ន្ធទី១៥.២៖ ប្រជាជនជនជាតិដើមភាគតិចកម្ពុជា និងប៉ុល ពត, ទិដ្ឋភាពរួមអំពីគម្រោងសំណង។

[103] ឧបសម្ព័ន្ធទី១៦.១៖ ការចូលមើល និងការផ្សព្វផ្សាយពីបណ្ណសារច្បាប់ និងប្រវត្តិសាស្ត្រទាក់ទងនឹងខ្មែរក្រហម, ទិដ្ឋភាពរួមអំពីគម្រោងសំណង។

[104] ឧបសម្ព័ន្ធទី១៦.៤៖ ការចូលមើល និងការផ្សព្វផ្សាយពីបណ្ណសារច្បាប់ និងប្រវត្តិសាស្ត្រទាក់ទងនឹងខ្មែរក្រហម, លិខិតពីក្រសួងអប់រំ យុវជន និងកីឡា។

សកម្មភាពគម្រោងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាប៉ាន់ស្មានថា កម្មវិធីនេះនឹងត្រូវប្រើប្រាស់ដោយប្រជាជនចំនួន ៣៦.៦៦០ នាក់។ ការអនុវត្តគម្រោងនេះមានរយៈពេលជាង ១៨ ខែ[105]។

71. គម្រោងនេះនឹងផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះជាច្រើនដែលពុំមានតំណាង តាមរយៈការថែរក្សា និងជំរុញកេរដំណែលរបស់ អ.វ.ត.ក ហើយនឹងជាមធ្យោបាយមួយនៃការចងចាំ ការអប់រំ និងការសិក្សាស្រាវជ្រាវអំពីកម្ពុជាប្រជាធិបតេយ្យ។

72. គម្រោងនេះពុំទាន់ទទួលបានការឧបត្ថម្ភថវិកានៅឡើយ។

## V. គម្រោងដែលស្នើឡើងដោយអង្គភាពគាំពារជនរងគ្រោះ

73. សហមេធាវីនាំមុខស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាលើគម្រោងចំនួនពីរ ក្រោមលក្ខខណ្ឌថា គម្រោងទាំងនេះទទួលបានការឧបត្ថម្ភថវិកាពេញលេញ ត្រឹមថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៧ និងទទួលបានឯកសារដែលត្រូវការបន្ថែមទៀត ទាក់ទងនឹងមជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍នៅភ្នំសំពៅ និងការធ្វើទុកបុកម្នេញលើពុទ្ធសាសនិកជនក្នុងរបបខ្មែរក្រហម[106]។ ប្រសិនបើអង្គជំនុំសាលាដំបូងច្រានចោលសំណើសុំពន្យារពេលនេះ សហមេធាវីនាំមុខនឹងដកគម្រោងនេះចេញពីការស្នើសុំការពិចារណា។ ប្រសិនបើសំណុំសុំពន្យារពេលត្រូវបានទទួលយក ហើយពុំមានព័ត៌មានបន្ថែមទាក់ទងនឹងស្ថានភាពថវិកាទេនោះ សហមេធាវីនាំមុខក៏នឹងដកគម្រោងនេះចេញពីការស្នើសុំការពិចារណាផងដែរ។

### (១៧) ការបោះពុម្ពផ្សាយ និងការចែកចាយសាលក្រមទាំងមូល និងសង្ខេបនៃសំណុំរឿង ០០២/០២ ដល់ដើមបណ្តឹងរដ្ឋប្បវេណី

---

[105] ឧបសម្ព័ន្ធទី១៦.១៖ ការចូលមើល និងការផ្សព្វផ្សាយពីបណ្ណសារច្បាប់ និងប្រវត្តិសាស្ត្រទាក់ទងនឹងខ្មែរក្រហម, ទិដ្ឋភាពរួមអំពីគម្រោងសំណង។

[106] សូមមើល *ដូចខាងលើ*, កថាខណ្ឌ ១៣។ ឧទាហរណ៍ កំពុងរងចាំការអនុញ្ញាតសម្រាប់ការប្រើប្រាស់ដី និងព័ត៌មានលម្អិតអំពីការរចនា/ការសាងសង់មជ្ឈមណ្ឌលសិក្សា។

74. អង្គភាពគាំពារជនរងគ្រោះ ដោយការគាំទ្រជាមួយសហមេធាវីនាំមុខ បានសហការជាមួយផ្នែកកិច្ចការសាធារណៈ[107] ដើម្បីបោះពុម្ពផ្សាយ និងចែកចាយសាលក្រម ទាំងមូល និងសង្ខេប នៃសំណុំរឿង ០០២ ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលនេះជាគម្រោងសំណងជាការទទួលស្គាល់របស់តុលាការ[108]។ គម្រោងនេះព្យាយាមបំពេញសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជាអ្នកចូលរួមក្នុងកិច្ចដំណើរការនីតិវិធី សិទ្ធិទទួលបានការជូនដំណឹង និងយល់ដឹងអំពីលទ្ធផលនៃសំណុំរឿង។ គម្រោងនេះមានរយៈពេលពីរឆ្នាំ[109]។

75. ការបោះពុម្ពផ្សាយ និងការចែកចាយសាលក្រម នឹងផ្ដល់ប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយផ្ដល់ពួកគាត់នូវព័ត៌មានអំពីសំណុំរឿងដែលពួកគាត់បានចូលរួម និងបង្កើតឱកាសដល់ក្រុមគ្រួសារ មិត្តភ័ក្រ សហគមន៍ និងជនរងគ្រោះជាច្រើនដែលពុំមានតំណាង ឲ្យពិភាក្សាអំពីប្រវត្តិខ្មែរក្រហម និងលទ្ធផលនៃសំណុំរឿង០០២/០២។ ផ្នែកកិច្ចការសាធារណៈបានបោះពុម្ព និងចែកចាយសាលក្រម ទាំងមូល និងសង្ខេប នៃសំណុំរឿង០០២/០២ ចំនួន ៣.៨៦៧ ច្បាប់ ដើម្បីចែកចាយដល់ដើមបណ្ដឹងរដ្ឋប្បវេណី[110]។

---

[107] ឧបសម្ព័ន្ធ ១៧.៣៖ ការបោះពុម្ពផ្សាយ និងការចែកចាយដល់ដើមបណ្ដឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២/០២ នូវសាលក្រម ទាំងមូល និងសេចក្ដីសង្ខេប, លិខិតពីផ្នែកកិច្ចការសាធារណៈ។

[108] ឧបសម្ព័ន្ធទី១៧៖ ការបោះពុម្ពផ្សាយ និងការចែកចាយដល់ដើមបណ្ដឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២/០២ នូវសាលក្រម ទាំងមូល និងសេចក្ដីសង្ខេប។ *សូមមើលផងដែរ* សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង០០២/០២, E352/2/1, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦, កថាខណ្ឌ១៣ និង ឧបសម្ព័ន្ធទី២៖ គម្រោងស្ថិតក្រោមការពិចារណា (គម្រោងទី៤), E352/2/1.2.2។

[109] ឧបសម្ព័ន្ធទី ១៧៖ ការបោះពុម្ពផ្សាយ និងការចែកចាយដល់ដើមបណ្ដឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២/០២ នូវសាលក្រម ទាំងមូល និងសេចក្ដីសង្ខេប, ទិដ្ឋភាពរួមអំពីគម្រោងសំណង។

[110] ផ្នែកកិច្ចការសាធារណៈបានដាក់បញ្ចូលការចំណាយលើការបោះពុម្ពនៅក្នុងការដាក់ស្នើថវិកាសម្រាប់ឆ្នាំសារពើព័ន្ធ ២០១៨។ ក្នុងដំណើរការថវិកានេះ រាល់ការប្ដេជ្ញាចិត្តទាំងអស់ គឺអាស្រ័យលើការអនុម័តថវិកា និងបន្ទាប់មក ការអនុម័តផ្នែកហិរញ្ញវត្ថុដោយការិយាល័យរដ្ឋបាល។ *សូមមើលផងដែរ* ឧបសម្ព័ន្ធទី ១៧.៣៖ ការបោះពុម្ពផ្សាយ និងការចែកចាយដល់ដើមបណ្ដឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២/០២ នូវសាលក្រមទាំងមូល និងសេចក្ដីសង្ខេប, អនុស្សរណៈអន្តរការិយាល័យពីផ្នែកកិច្ចការសាធារណៈ។

76. គម្រោងនេះទទួលបានការឧបត្ថម្ភថវិកាមួយចំនួនហើយ[111]។

### (១៨) មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍នៅភ្នំសំពៅ និងការធ្វើទុកបុកម្នេញលើពុទ្ធសាសនិកជនក្នុងរបបខ្មែរក្រហម

77. អង្គភាពជនរងគ្រោះ សហការជាមួយអង្គការយុវសន្តិភាព និងវិទ្យាស្ថានសន្តិភាពកម្ពុជា និងសហមេធាវីនាំមុខ ខិតខំបង្កើតគម្រោងសំណងដែលបានស្នើឡើងមួយ គឺ "មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍នៅភ្នំសំពៅ និងការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិកជនក្នុងរបបខ្មែរក្រហម" [112]។ គម្រោងនេះស្នើឱ្យសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍នៅភ្នំសំពៅ ដើម្បីបង្កើតបរិយាកាសប្រកបដោយសុវត្ថិភាពដល់ដើមបណ្តឹងរដ្ឋប្បវេណី និងសមាជិកសហគមន៍ សម្រាប់ការសន្ទនាអន្តរជំនាន់ ការថ្លែងពីការពិត និងការរំឮកការចងចាំ។ គម្រោងនេះព្យាយាមយកចិត្តទុកដាក់លើការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិកក្នុងរបបខ្មែរក្រហម តាមរយៈការរៀបចំឯកសារ និងសកម្មភាពអប់រំ។ តាមការរំពឹងទុក គម្រោងនេះមានរយៈពេល ៣៦ ខែ[113]។

78. គម្រោងនេះមានគោលដៅផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈសកម្មភាពអប់រំ និងការសន្ទនាអន្តរជំនាន់។ គម្រោងនេះនឹងធ្វើឱ្យមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណី ដែលរស់នៅជិតភ្នំសំពៅ និងរៀបចំឯកសារអំពីបទពិសោធន៍របស់ពួកគាត់អំពីការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិកជនក្នុងរបបខ្មែរក្រហម ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៨៧ នាក់ ត្រូវបានទទួលស្គាល់ ផ្អែកលើការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិកជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

**79.** គម្រោងនេះពុំទាន់ទទួលបានការឧបត្ថម្ភថវិកានៅឡើយ ហើយនៅរង់ចាំឯកសារមួយចំនួនទៀត។

---

[111] ឧបសម្ព័ន្ធទី ១៧.៣៖ ការបោះពុម្ពផ្សាយ និងការចែកចាយដល់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២/០២ នូវសាលក្រមទាំងមូល និងសេចក្តីសង្ខេប, អនុស្សរណៈអន្តរការិយាល័យពីផ្នែកកិច្ចការសាធារណៈ។

[112] ឧបសម្ព័ន្ធទី១៨៖ មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍នៅភ្នំសំពៅ និងការធ្វើទុកបុកម្នេញលើពុទ្ធសាសនិកជនក្នុងរបបខ្មែរក្រហម។

[113] ឧបសម្ព័ន្ធទី១៨៖ មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍នៅភ្នំសំពៅ និងការធ្វើទុកបុកម្នេញលើពុទ្ធសាសនិកជនក្នុងរបបខ្មែរក្រហម, ទិដ្ឋភាពរួមអំពីគម្រោងសំណង។

## V. សំណើ

80. សហមេធាវីនាំមុខសូមរម្លឹកពីសំណើរបស់ខ្លួននៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ដែលសហមេធាវីនាំមុខស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ព្យសនកម្ម ដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ដោយសារតែការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលតុលាការរកឃើញថាជនជាប់មានពិរុទ្ធភាព[114]។

**អាស្រ័យហេតុនេះ** សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើដោយសេចក្តីគោរពដល់អង្គជំនុំជម្រះសាលាដំបូង៖

*ទាក់ទងនឹងគម្រោងដែលបានស្នើឡើងនៅក្នុង**ផ្នែកទី ២***

(១) **ទទួលស្គាល់**ថា គម្រោងនីមួយៗដែលបានស្នើឡើងនៅក្នុងផ្នែកទី ២ ឆ្លើយតបទៅនឹងព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងដោយសារតែការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលតុលាការរកឃើញថាជនជាប់មានពិរុទ្ធភាព។

(២) **អនុម័តលើ**គម្រោងនីមួយៗដែលបានស្នើឡើងនៅក្នុងផ្នែកទី ២ ថាផ្តល់សំណងសមស្របតាមការទាមទាររបស់សហមេធាវីនាំមុខ។

*ទាក់ទងនឹងគម្រោងដែលបានស្នើនៅក្នុង**ផ្នែកទី ៤ និងទី ៥***

(១) **យល់ព្រមតាម**សំណើសុំការពន្យារពេលកំណត់សម្រាប់ការរៃអង្គាសមូលនិធិដល់ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៧ សម្រាប់គម្រោងចំនួន ៦ នៅក្នុងផ្នែកទី ៤ និងផ្នែកទី ៥ និងទទួលយកឯកសារពីការធានាមូលនិធិពេញលេញ ត្រឹមកាលបរិច្ឆេទខាងលើនេះ។

(២) *ប្រសិនបើមានការអនុញ្ញាតដល់ការពន្យារពេល និងទទួលបានភស្តុតាងនៃការធានាមូលនិធិ* **ទទួលស្គាល់**ថា គម្រោងនីមួយៗដែលបានស្នើឡើងនៅក្នុងផ្នែកទី៤ និងផ្នែកទី៥ ដែលទទួលបានការធានាមូលនិធិពេញលេញ ត្រឹមកាលបរិច្ឆេទខាងលើនេះ ឆ្លើយតបទៅនឹងព្យសនកម្មដែលដើម

---

[114] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២/០២, **E457/6/2**, ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧, សេចក្តីសម្រេច។

បណ្ដឹងរដ្ឋប្បវេណីបានទទួលរងដោយសារតែការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលតុលាការរកឃើញថាជនជាប់មានពិរុទ្ធភាព និង**អនុម័តគម្រោងនីមួយ**ដែលបានស្នើឡើងនៅក្នុងផ្នែកទី២ ថាបានផ្ដល់សំណងសមស្របតាមការទាមទាររបស់សហមេធាវីនាំមុខ។

(៣) **ចាត់ទុកថាមានការ**ដកគម្រោងដែលស្នើឡើងនៅក្នុងផ្នែកទី៤ និងផ្នែកទី៥ *ប្រសិនបើពុំមានការអនុញ្ញាតលើសំណើសុំការពន្យារពេល ឬពុំទទួលបានការធានាមូលនិធិពេញលេញ នៅពេលនោះ។*

*ទាក់ទងនឹងគម្រោងដែលបានស្នើនៅក្នុង**ផ្នែកទី ៣** សហមេធាវីនាំមុខអន្តរជាតិស្នើដោយក្ដីគោរពឲ្យអង្គជំនុំជម្រះសាលាដំបូង*

(១) **ទទួលស្គាល់**ថា គម្រោងនីមួយដែលបានស្នើនៅក្នុងផ្នែកទី ៣ ឆ្លើយតបទៅនឹងព្យសនកម្មដែលដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរងដោយសារតែការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលតុលាការរកឃើញថាជនជាប់មានពិរុទ្ធភាព។

(២) **អនុម័ត**គម្រោងនីមួយៗដែលបានស្នើឡើងនៅក្នុងផ្នែកទី ៣ ថាបានផ្ដល់សំណងសមស្របតាមការទាមទាររបស់សហមេធាវីនាំមុខ។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | [signature] |
| | Marie GUIRAUD<br>សហមេធាវីនាំមុខ | ភ្នំពេញ | [signature] |